**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឌិន ដូរ៉ា**

**ចេង ច័ន្ទឫទ្ធី**

សាស្ត្រាចារ្យណែនាំ

លោក **គឹម ស៊ីវៀង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **ខិន ដូរ៉ា** និង **ចេង ច័ន្ទឫទ្ធី** ជានិស្សិតនៃសកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពថ្លែងអំណរគុណយ៉ាងធំធេងជូនចំពោះលោកឪពុក និងគោរពជូនចំពោះអ្នកម្តាយ ដែលលោកទាំងពីរជាអ្នកមានគុណចំពោះរូបកូន និងបងប្អូនប្រុសស្រី ដែលបានជួយជ្រោមជ្រែងលើកទឹកចិត្ត។ ជាងនេះទៅទៀតនោះ លោកទាំងពីរបានផ្តល់នូវសេចក្តីស្រឡាញ់ ដំបូន្មាន ការអប់រំ និងការប្រៀនប្រដៅផ្តល់ជាកំលាំងចិត្តព្រមទាំងផ្តល់នូវភាពកក់ក្តៅដល់រូបកូន។

សូមថ្លែងអំណរគុណចំពោះសាកលវិទ្យាធិការ គឺឯកឧត្តមបណ្ឌិត លុយ ចណ្ណា ដែលបានដឹកនាំ និងគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសស្ត្រសេដ្ឋកិច្ច ដែលជាកន្លែងផ្តល់ចំណេះដឹង និងជាកន្លែងអប់រំដែលប្រកបដោយប្រសិទ្ធិភាព និងខ្ពង់ខ្ពស់សម្រាប់សិស្ស និស្សិត ដើម្បីទទួលបាននូវពុទ្ធិក្នុងការកសាងអនាគតខ្លួនឯង គ្រួសារ និងសង្គមជាតិឲ្យមានភាពរីកចម្រើនការអភិវឌ្ឍន៍ប្រកបដោយសាមគ្គីភាព សន្តិភាព និងសច្ចភាព។

សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យទាំងអស់ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ធនធាន លះបង់ទាំងកំលាំងកាយ ចិត្តក្នុងការបង្ហាត់បង្រៀន និងផ្តល់នូវដំបូន្មានប្រកបដោយឧត្តមគតិដល់រូបខ្ញុំ ព្រមទាំងនិស្សិតផ្សេងទៀត ក្នុងគោលបំណងតែមួយ គឺដើម្បីឲ្យកុលបុត្រធីតាខ្មែរទទួលបានចំណេះវិជ្ជាប្រកបដោយឧត្តមភាព ដើម្បីចូលរួមចំណែកក្នុងការកសាងប្រទេសជាតិ មាតុភូមិ។

សូមថ្លែងអំណរគុណចំពោះឧត្តមមិត្តទាំងអស់ដែលបានផ្តល់ការណែនាំ ព្រមទាំងបានចែករំលែកនូវធនធាន និងចំណេះវិជ្ជាចំពោះគ្នាទៅវិញទៅមកប្រកបដោយស្មោមញញឹម។

សូមថ្លែងអំណរគុណចំពោះក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធដែលបានចងក្រង និងរៀបចំប្រព័ន្ធច្បាប់ ក៏ដូចជាឯកសារច្បាប់នានា ដែលជាការរួមចំណែកមួយក្នុងការអប់រំផ្នែកសិលធម៌ ព្រមទាំងកែប្រែប្រព័ន្ធច្បាប់ បានកំណត់អំពីព្រំដែននៃសិទ្ធិ និងការអនុវត្តសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូបដើម្បីឲ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម។

# អារម្ភកថា

ក្នុងនាមខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយក៏ជាអ្នករៀបរៀងសៀវភៅនេះ ខ្ញុំសូមជំរាបដល់មិត្តអ្នកអានទាំងអស់ថា សៀវភៅនេះត្រូវបានចងក្រងឡើងដើម្បីបំពេញនូវកាតព្វកិច្ច និងស្រាវជ្រាវនូវប្រធានបទស្តីអំពី "បណ្តឹងឧបាស្រ័យ" សំរាប់នៅក្នុងឆ្នាំទី ៤ និងដើម្បីជាជំនួយដល់មិត្តអ្នកអានទទួលបានចំណេះដឹងបន្ថែមខាងផ្នែកច្បាប់។ ជាពិសេស គឺជួយឲ្យអ្នកទាំងអស់គ្នាទទួលបាននូវពុទ្ធិបន្ថែមទៀតដែលជាកត្តាមួយចាំបាច់ សម្រាប់កសាងប្រទេសជាតិឲ្យកាន់តែមានភាពរីកចម្រើន មានសាមគ្គីភាព មានសន្តិភាព និងការអភិវឌ្ឍន៍បន្ថែមទៀត។ គោលបំណងនៃសៀវភៅនេះ ធ្វើឲ្យអ្នកបានយល់ដឹងបន្ថែមទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីបន្ថែមទៀត។

ចំណេះដឹងគឺជាអំណាច និងជាអាវុធដ៏មុទស្រួច សម្រាប់ធ្វើឲ្យមនុស្សមិនឆាប់ចាញ់បោកគេ ធ្វើឲ្យមនុស្សមានភាពក្លាហាន និងចេះដោះស្រាយរាល់បញ្ហាដែលកើតមានឡើងចំពោះខ្លួន ចំពោះនគ្រួសារ និងសង្គមជាតិទាំងមូល។ ចំណេះវិជ្ជាគឺជាពន្លឺបំភ្លឺផ្លូវ ដែលនាំឲ្យយើងដើរតាមផ្លូវត្រូវ និងមិនធ្លាក់ក្នុងផ្លូវខុស។ សៀវភៅនេះជួយពង្រីកពុទ្ធិផ្នែកច្បាប់ដល់ប្រិយមិត្តអ្នកអានទាំងអស់សម្រាប់យកទៅប្រើប្រាស់ជាមធ្យោបាយក្នុងការដឹកនាំប្រទេស ដឹកនាំមុខរបប មុខជំនួញ ឬដឹកនាំដំណើរជីវិតរស់នៅរបស់គ្រួសារខ្លួនឲ្យផុតពីភាពទាល់ច្រកនានាពោលគឺឲ្យមានអត្ថិភាពប្រសើរក្នុងជីវិត។

ប្រទេសជាតិមួយមានការរីកចម្រើនលូតលាស់ នឹងមានការអភិវឌ្ឍន៍បានលុះត្រាតែសិស្ស-និស្សិត ឬប្រជាជននៃប្រទេសនោះមានចំណេះដឹងខ្ពង់ខ្ពស់ មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងបានល្អ មានសណ្តាប់ធ្នាប់ល្អ និងមានសុខសន្តិភាព។ ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរអរគុណយ៉ាងក្រៃលែង ចំពោះ ឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ និស្សិត មិត្តអ្នកអានទាំងអស់ដែលបានយកចិត្តទុកដាក់ក្នុងការអានសៀវភៅរបស់ខ្ញុំ ដែលបានចំណាយពេលដ៏មានតម្លៃ ជាពិសេសសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ និងជូនពរឱ្យជួបប្រទះតែសេចក្តីសុខ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។ សូមអរគុណ!!!

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..... **១**

**ជំពូកទី ១**

**សញ្ញាណទូទៅនៃ បណ្តឹងឧបាស្រ័យ**

**ផ្នែកទី ១៖ អត្ថន័យនៃបណ្តឹងឧបាស្រ័យ** ..... **៣**

១. ទស្សនៈក្នុងបណ្តឹងឧបាស្រ័យ ..... ៣

២. ការធ្វើបណ្តឹងឧបាស្រ័យ ..... ៣

**ផ្នែកទី ២៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ** ..... **៤**

១. ការសង្គ្រោះសិទ្ធិរបស់ភាគី ..... ៤

២. ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬផ្តល់យុត្តិធម៌ដល់ភាគី ..... ៥

**ផ្នែកទី ៣៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង បណ្តឹងឧបាស្រ័យ** ..... **៥**

១.បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ..... ៥

២. បណ្តឹងឧបាស្រ័យ ..... ៦

**ជំពូកទី ២**

**ប្រភេទនៃបណ្តឹងឧបាស្រ័យ**

**ផ្នែកទី ១៖ បណ្តឹងឧទ្ធរណ៍** ..... **៧**

១. របៀបធ្វើបណ្តឹងឧទ្ធរណ៍ ..... ៧

២. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ..... ១១

៣. អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ..... ១២

៤. ការជំនុំជម្រះរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ..... ១៤

៥. ការដកបណ្តឹងឧទ្ធរណ៍ ..... ១៥

៦. បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ..... ១៦

៧. ការវិនិច្ឆ័យ និងការចេញសាលដីកា ..... ១៧

៨. វិសាលភាពនៃការលុបចោល និង ការផ្លាស់ប្តូរ ..... ២២

**ផ្នែកទី ២៖ បណ្តឹងសាទុក្ខ** ..... **២៣**

១. អត្ថន័យនៃបណ្តឹងសាទុក្ខ ..... ២៣

២. មូលហេតុនៃបណ្តឹងសាទុក្ខ ..... ២៤

៣. ការធ្វើបណ្ដឹងសាទុក្ខ ........................................................................ ២៥
៤. នីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងសាទុក្ខ និងការចេញសាលដីកា.................. ២៦
៥. សាលដីកាទទួលស្គាល់នូវបណ្ដឹងសាទុក្ខ .....................................................២៧
**ផ្នែកទី ៣៖ បណ្ដឹងជំទាស់**......................................................................................**៣១**
១. អត្ថន័យនៃបណ្ដឹងជំទាស់ ..........................................................................៣១
២. មូលហេតុនៃបណ្ដឹងជំទាស់ .......................................................................៣១
៣. ដំណើរការនៃបណ្ដឹងជំទាស់.........................................................................៣១
៤. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្ដឹងជំទាស់.................................................៣៣
៥. ប្រភេទដីកាសម្រេចដែលអាចប្ដឹងជំទាស់បាន ...............................................៣៥
៦. វិសាលភាពនៃបណ្ដឹងជំទាស់.........................................................................៣៩
**សេចក្តីសន្និដ្ឋាន**........................................................................................................**៤២**
**អនុសាសន៍**............................................................................................................**៤៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការទំនាក់ទំនងគ្នា រវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ឬពីគ្រួសារមួយទៅ គ្រួសារមួយ ឬពីរដ្ឋមួយទៅរដ្ឋមួយ តែងតែមានការជួបប្រទះនូវបញ្ហាផ្សេងៗដែលមិនអាចគេចផុតទេ។ ចំពោះទំនាក់ទំនងរវាងកម្មករនិយោជិត និងនិយោជក ក៏មិនអាចគេចផុតពីវិវាទដែរ។ ការមានជម្លោះនឹងគ្នា អាចជាជម្លោះ វិវាទដីធ្លី វិវាទពាណិជ្ជកម្ម វិវាទប្តីប្រពន្ធមិនចុះសម្រុងនឹងគ្នា វិវាទកូនចៅដែលទាក់ទងនឹងទ្រព្យសម្បត្តិ និងវិវាទផ្សេងៗទៀត។

ដើម្បីធ្វើឱ្យមានការស្ងប់អារម្មណ៍ និងមានភាពអស់ចិត្តនូវជម្លោះក្តីក្តាំរបស់ភាគី នោះភាគីនៃជម្លោះនោះតែងតែរិះរកវិធីដោះស្រាយ។ វិធីដោះស្រាយអាចជាវិធីដោះស្រាយ ក្រៅប្រព័ន្ធតុលាការតាមរយៈអាជ្ញាកណ្តាល មេឃុំ ចៅសង្កាត់ មជ្ឈត្តករការងារ មជ្ឈត្តកម្មពាណិជ្ជកម្ម និងវិធីដោះស្រាយវិវាទតាមផ្លូវតុលាការ។ យន្តការចុងក្រោយនេះ ត្រូវបានច្បាប់រៀបចំផ្តល់សិទ្ធិអំណាចដល់ស្ថាប័ន ៣ គឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។

ដោយសារនៅក្នុងរឿងក្តីរដ្ឋប្បវេណី នៅពេលដែលមានវិវាទកើតឡើង ភាគីនឹងត្រូវបានបាត់បង់ផលប្រយោជន៍មួយចំនួនដូចជា ពេលវេលា លុយកាក់ និងការចំណាយ ផ្សេងៗ និងពេលខ្លះក៏ធ្វើឱ្យមានការប៉ះពាល់ការទំនាក់ទំនងដោយសារតែមានវិវាទ។ ចំពោះការទំនាក់ទំនងនៅក្នុងការរស់នៅសព្វថ្ងៃ វាជារឿងដែលមិនអាចចៀសវាងបានឡើយ ដែលមនុស្សគ្រប់ៗរូបត្រូវតែជួបប្រទះនៅក្នុងការប្រាស្រ័យទាក់ទងគ្នានៅក្នុង សង្គម ពីព្រោះមនុស្សមិនអាចរស់នៅក្នុងសង្គមមួយដែលមិនមានទំនាក់ទំនងគ្នាបានទេ។ នៅក្នុងរឿងក្តីរដ្ឋប្បវេណី ការដោះស្រាយវិវាទជំហានដំបូងគឺជាសមត្ថកិច្ចរបស់សាលាដំបូងដែលហៅថា តុលាការជាន់ទាប ដែលមាននៅគ្រប់ខេត្តក្រុង។ ប្រសិនបើភាគីណាដែលបានបាត់ផលប្រយោជន៍នៅក្នុងរឿងក្តី ឬភាគីដែលឈ្នះក្តីហើយទទួលបានផលប្រយោជន៍មិនបានដូចបំណង ឬក៏ភាគីនៅតែមិនអាចដោះស្រាយវិវាទដោយស្មោះស្ម័គ្រ ឬភាគីបានព្រមព្រៀងគ្នាហើយ ភាគីនៅតែមិនអាចជ្រើសមធ្យោបាយណាមួយដើម្បីធ្វើការដោះស្រាយវិវាទទេ ភាគីអាចដាក់ពាក្យប្តឹងទៅ តុលាការជាន់ខ្ពស់ដើម្បីបន្តនីតិវិធីទាមទារអ្វីដែលខ្លួនចង់បាន។ ចំពោះការដាក់ពាក្យប្តឹងទៅតុលាការជាន់ខ្ពស់នោះ គេហៅថា **បណ្តឹងឧបាស្រ័យ** គឺជា សមត្ថកិច្ចរបស់ សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន លុះត្រាតែសេចក្តីសម្រេចរបស់តុលាការជាន់ទាប ឬសេចក្តីសម្រេចរបស់សាលាដំបូងមិនទាន់ចូលជាស្ថាពរ។ សេចក្តីសម្រេចរបស់តុលាការជាន់ទាប មាន ២ប្រភេទ គឺ ប្រភេទជា

ដីកាសម្រេច និងប្រភេទជាសាលក្រម។ ចំពោះការធ្វើបណ្ដឹងឧបាស្រ័យ ភាគីអាចប្ដឹងទៅតុលាការជាន់ខ្ពស់គ្រប់សេចក្ដីសម្រេចរបស់តុលាការជាន់ទាប។ ចំពោះសេចក្ដីសម្រេចដែលចេញជា ប្រភេទដីកាសម្រេចទាល់តែច្បាប់ចែងថាដីកាសម្រេចណាដែលអាចធ្វើបណ្ដឹងឧបាស្រ័យបានទើបភាគីអាចធ្វើបានពីព្រោះប្រភេទដីកាសម្រេចខ្លះភាគីមិនអាចប្ដឹងឧបាស្រ័យបានទេ លុះតែច្បាប់បានចែងច្បាស់ថា ដីកាសម្រេចនោះអាចប្ដឹងឧបាស្រ័យបាន។ តែចំពោះសេចក្ដីសម្រេចដែលចេញជាសាលក្រមវិញភាគីអាចធ្វើ បណ្ដឹងឧបាស្រ័យបានដោយច្បាប់មិនបានហាមឃាត់ឡើយ ប្រសិនបើភាគីចង់ប្ដឹងដោយ ភាគីគិតថាខ្លួនបានបាត់បង់ផលប្រយោជន៍ ឬមិនពេញចិត្តនឹងសេចក្ដីសម្រេចនោះ។

តើបណ្ដឹងឧបាស្រ័យជាអ្វី ហើយមានសារៈប្រយោជន៍អ្វីខ្លះក្នុងការធ្វើបណ្ដឹងនេះ?

ដើម្បីឱ្យប្រធានបទនៃបណ្ដឹងឧបាស្រ័យនេះមានភាពកាន់តែច្បាស់លាស់និងលម្អិតថែមទៀតនោះគឺគួរតែសិក្សាទៅលើ ០២ផ្នែក។ ផ្នែកទី ០១ និយាយអំពី សញ្ញាណទូទៅ ដែលចែកជា ៣ កថាខណ្ឌ គឺកថាខណ្ឌទី១៖ អត្ថន័យនៃបណ្ដឹងឧបាស្រ័យ កថាខណ្ឌទី២៖ គោលបំណងនៃបណ្ដឹងឧបាស្រ័យ និង កថាខណ្ឌទី៣៖ ភាពខុសគ្នារវាងបណ្ដឹងទាមទារឱ្យមានការជំនុំជម្រះសាជាថ្មី និងបណ្ដឹងឧបាស្រ័យ។ ចំពោះផ្នែកទី ២ គឺនិយាយអំពី ប្រភេទនៃបណ្ដឹងឧបាស្រ័យដែលចែកជា ០៣ កថាខណ្ឌ គឺកថាខណ្ឌទី១៖ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២៖ បណ្ដឹងសាទុក្ខ និងកថាខណ្ឌទី៣៖ បណ្ដឹងជំទាស់។

# ជំពូកទី ១
# សញ្ញាណទូទៅនៃ បណ្ដឹងឧបាស្រ័យ

មុននឹងធ្វើការសិក្សាអំពីប្រភេទបណ្ដឹងនីមួយៗ នៃបណ្ដឹងឧបាស្រ័យត្រូវស្វែងយល់អោយច្បាស់ ពីសញ្ញាណទូទៅនៃបណ្ដឹងឧបាស្រ័យ ជាមុនសិន ហេតុដូច្នេះហើយក្នុងគោលបំណង និងអត្ថន័យនៃបណ្ដឹងឧបាស្រ័យនេះ នឹងត្រូវបានធ្វើការបកស្រាយនៅខាងក្រោម។

## ផ្នែកទី ១៖ អត្ថន័យនៃបណ្ដឹងឧបាស្រ័យ

បណ្ដឹងឧបាស្រ័យ គឺជាបណ្ដឹងទៅតុលាការជាន់ខ្ពស់ ដែលទាមទារដោយភាគីទៅតុលាការអោយលុបចោល ឬផ្លាស់ប្ដូរនូវសេចក្ដីដែលចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមបានចូលជាស្ថាពរដែលសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម រួមមាន៖ បណ្ដឹងឧទ្ធរណ៍ បណ្ដឹងសាទុក្ខ និងបណ្ដឹងជំទាស់។

### ១. ទស្សនៈក្នុងបណ្ដឹងឧបាស្រ័យ

ចំពោះបណ្ដឹងឧបាស្រ័យ គឺធ្វើឡើងដើម្បីលុបចោល ឬកែប្រែនូវសេចក្ដីសម្រេចដែលភាគីណាមួយមិនពេញចិត្ត (សាលក្រម ឬសាលដីកា ឬដីកាសម្រេច) ដោយភាគីដែលបានទាមទារនៅក្នុងបណ្ដឹងឧបាស្រ័យ។ ចំពោះសេចក្ដីសម្រេចនេះ គឺជាសេចក្ដីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម។ មុនពេលដែលសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម មិនចូលជាស្ថាពរ គឺភាគីអាចប្រើប្រាស់នូវបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។[1]

ហេតុដូចនេះហើយ អាចនិយាយបានថាបើសេចក្ដីសម្រេចនោះចូលជាស្ថាពរ គឺមិនអាចធ្វើបណ្ដឹងឧបាស្រ័យបានទេ នេះមិនមានន័យថា មិនអាចធ្វើបណ្ដឹងទៅតុលាការជាន់ខ្ពស់នោះទេ គឺអាចធ្វើបាន ដោយប្រើបណ្ដឹងផ្សេងទៀត ក្រៅពីបណ្ដឹងឧបាស្រ័យ ដែលមានបណ្ដឹងទាមទារអោយជំនុំជម្រះសារជាថ្មីជាដើម ហើយចំពោះអានុភាពនៃបណ្ដឹងឧបាស្រ័យ គឺបានបង្អាក់នូវការចូលជាស្ថាពររបស់សេចក្ដីសម្រេចជាដើម គឺត្រូវរងចាំនៅនីតិវិធីនៃបណ្ដឹងឧបាស្រ័យចប់សិន ។

### ២. ការធ្វើបណ្ដឹងឧបាស្រ័យ

ក្នុងការធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ភាគីអាចធ្វើបណ្ដឹងបានតែចំពោះសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមដែលមិនទាន់បានចូលជាស្ថាពរនោះទេ ក៏ប៉ុន្តែចំពោះសេចក្ដី

[1] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សម្រេចរបស់តុលាការថ្នាក់ក្រោមចូលជាស្ថាពរក៏ដោយ ក៏ភាគីនៅតែមានសិទ្ធិប្រើប្រាស់បណ្តឹងទៅតុលាការដដែល។[2] ឧទាហរណ៍ បណ្តឹងទាស់ និងសាលក្រមកំបាំងមុខ ឬបណ្តឹងតវ៉ា។ ចំពោះសាលក្រម ឬសាលដីកាភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខបាន ប៉ុន្តែដីកាសម្រេចរបស់តុលាការថ្នាក់ក្រោម អាចធ្វើបណ្តឹងឧបាស្រ័យបាន លុះត្រាតែមានចែងក្នុងច្បាប់ ថាដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ទើបភាគីមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យបាន។ កាលណាភាគីដែលបានធ្វើបណ្តឹងជំទាស់ម្តងរួចទៅហើយ លើដីកាសម្រេចដែលមានចែងក្នុងច្បាប់នោះ គឺភាគីនៅក្នុងបណ្តឹងឧបាស្រ័យនោះមិនអាចធ្វើបណ្តឹងជំទាស់ម្តងទៀតបានទេទៅលើដីកាសម្រេចចំពោះបណ្តឹងជំទាស់មុននោះឡើយ។[3]

ប្រសិនបើមានបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេចចុងក្រោយរបស់តុលាការជាន់ទាបជាគោលការណ៍សេចក្តីសម្រេចរបស់តុលាការនោះ នៅក្នុងដំណើរការរឿងក្តីរហូតដល់ចេញសាលក្រមចុងក្រោយត្រូវទទួលនូវ ការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ចំពោះសេចក្តីសម្រេចចុងក្រោយនោះទេ។ ដើម្បីឱ្យមានស្ថេរភាពនៅក្នុងដំណើរការនីតិវិធី ប្រសិនបើតុលាការដែលទទួលបណ្តឹងឧបាស្រ័យចំពោះចំណុចបន្ទាប់បន្សំដែលទាក់ទងនិងដំណើរការ នៃនីតិវិធីដោយឡែកចំពោះសាលក្រមចុងក្រោយដើម្បីដោះស្រាសចំណុចបន្ទាប់បន្សំឱ្យបានចូលជាស្ថារពឱ្យបានឆាប់រហ័ស ហើយមានភាពសម រម្យ។ ការទទួលស្គាល់បណ្តឹងឧបាស្រ័យនេះ គឺដើម្បីបន្ថយនូវបណ្តឹងឧបាស្រ័យនេះចំពោះសាលក្រមចុងក្រោយដោយសារតែមានបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ។

## ផ្នែកទី ២៖ គោលបំណងនៃបណ្តឹងឧបាស្រ័យ

នៅក្នុងផ្នែកនេះនឹងធ្វើការបកស្រាយនូវគោលបំណង នៃបណ្តឹងឧបាស្រ័យនេះតាមរយៈទស្សនៈលើបណ្តឹងឧបាស្រ័យ និងការប្រើប្រាស់បណ្តឹងឧបាស្រ័យ។

### ១. ការសង្គ្រោះសិទ្ធិរបស់ភាគី

ការវិនិច្ឆ័យរបស់តុលាការ គឺធ្វើឡើងដោយមនុស្ស ឬការភ័ន្តច្រលំកើតមានដោយចៀសមិនរួច ពីព្រោះការសម្រេចរបស់តុលាការពេលខ្លះមិនប្រាកដថាត្រឹមត្រូវទាំងអស់នោះទេដោយសារតែតុលាការមិនបានពិនិត្យ ភស្តុតាង ឬឯកសារផ្សេងៗឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ ដែលជាហេតុធ្វើឱ្យសេចក្តីសម្រេចរបស់តុលាការដែលមិនមានភាពត្រឹមត្រូវប្រសិនបើទុកឱ្យស្ថានភាពនៅដូច្នោះ

[2] បណ្តឹងតុលាការដែលមានដូចជា បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បណ្តឹងជំទាស់ និងបណ្តឹងតវ៉ា។

[3] មាត្រា ២៥៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

កំហុសនោះ គឺមិនត្រឹមតែបំពានសិទ្ធិរបស់ភាគីប៉ុណ្ណោះទេ គឺធ្វើឱ្យបាត់បង់ជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការតែម្តង។ ដូច្នេះហើយ ចាំបាច់ត្រូវតែមាននូវប្រព័ន្ធមួយដែលតាមរយៈនោះ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន តាមពាក្យសុំរបស់ភាគីណាមួយដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ។ កាលណាភាគីណាម្ខាងមិនសុខចិត្ត ឬក៏មិនពេញនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដើម្បីទាមទារអ្វីដែលខ្លួនចង់បានដូច្នេះហើយទើបច្បាប់អនុញ្ញាតឱ្យភាគីមិនសិទ្ធិធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់ដែលហៅថា ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ បើសិនជាភាគីមិនមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទេនោះ ភាគីត្រូវតែទទួលនូវសេចក្តីសម្រេចនោះតែម្តងដោយមិនអស់ចិត្តនឹងសេចក្តីសម្រេចនោះដោយបាត់បង់ផលប្រយោជន៍ណាមួយដែលខ្លួនមិនទាន់ចង់បាន។

### ២. ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬផ្តល់យុត្តិធម៌ដល់ភាគី

តាមរយៈការសម្រេចសេចក្តីរបស់តុលាការជាន់ទាប មិនត្រឹមត្រូវតុលាការជាន់ខ្ពស់ជាងនេះអាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះបាន។ ដែលគេហៅថា របបនេះជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ ដោយសារតែរបបបណ្តឹងទៅតុលាការជាន់ខ្ពស់ គឺជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់ កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរងចាំពាក្យសុំឧបាស្រ័យ ហេតុដូច្នេះ យើងអាចហៅផងដែរថា របបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិរបស់ភាគីឱ្យរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬកំហុសក្នុងនីតិវិធីក្នុងការជំនុំជម្រះ។ ម្យ៉ាងទៀតតាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្តីជាច្រើនដែលត្រូវពិនិត្យ និងធ្វើការជំនុំជម្រះសារឡើងវិញដោយតុលាការជាន់ខ្ពស់ចុងក្រោយបំផុត គឺត្រូវជម្រះដោយតុលាការជាន់ខ្ពស់ ដែលមានតែមួយចុងក្រោយគេគឺតុលាការកំពូល។

## ផ្នែកទី ៣៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងបណ្តឹងឧបាស្រ័យ

### ១.បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារអោយជំនុំជម្រះសាជាថ្មី គឺជាមធ្យោបាយឧបាស្រ័យមិនប្រក្រតីមួយដែលភាគីប្តឹងទាមទារអោយតុលាការដែលចេញសាលក្រម ឬសាលដីកានោះ និងអោយជំនុំជម្រះអំពីរឿងក្តីសាជាថ្មី ដោយយកមូលហេតុថា នីតិវិធីនៃបណ្តឹងនោះមានវិការៈធ្ងន់ធ្ងរ ឬឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យនោះមានការខ្វះខាតមិនប្រក្រតី។ ម្យ៉ាងវិញទៀតភាគីអាចដាក់ពាក្យសុំ

អោយជំនុំជម្រះសាជាថ្មីបាន ចំពោះដីកាសម្រេចចូលជាស្ថាពរហើយ។ ក្នុងចំណោមដីកាសម្រេច ដែលធ្វើឡើងដើម្បីជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយ ហើយបើមានមូលហេតុនៃ ការជំនុំជម្រះសាជាថ្មីក្នុង ដីកាសម្រេចនោះភាគីអាចប្តឹងទាមទារអោយជំនុំជម្រះសាជាថ្មីដែលខុស ពីបណ្តឹងឧបាស្រ័យ។ សមត្ថកិច្ចឱ្យជំនុំជម្រះសារជាថ្មី គឺជាសមត្ថកិច្ចរបស់តុលាការកំពូល។ ការ ប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺត្រូវមានមូលហេតុ ដែលមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ២. បណ្តឹងឧបាស្រ័យ

ចំពោះបណ្តឹងឧបាស្រ័យវិញ គឺភាគីមានសិទ្ធិប្តឹងទៅតុលាការជាន់ខ្ពស់ ប្រសិនបើគិតថាខ្លួន បានបាត់បង់ផលប្រយោជន៍។ ប៉ុន្តែការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ លុះត្រាតែ សេចក្តី សម្រេចរបស់តុលាការអាចជា សាលក្រម សាលដីកា ឬដីកាសម្រេចមិនទាន់ចូលជាស្ថាពរ ផ្ទុយពី បណ្តឹងឱ្យជំនុំជម្រះសាជាថ្មី ដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ ក៏អាចប្តឹងបានដែរ ដើម្បីកែ ប្រែ ឬលុបចោលនូវសេចក្តីសម្រេចដើម។

# ជំពូកទី ២
# ប្រភេទនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានបីប្រភេទ គឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។ ចំពោះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម និងសាលដីកា។ សម្រាប់បណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច។[4]

ហេតុដូច្នេះហើយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានប្រភេទផ្សេងៗគ្នា ដែលបែងចែកទៅតាមប្រភេទនៃសេចក្តីសម្រេចដើមដែលក្នុងនោះបុគ្គលដែលមានបំណងដាក់ពាក្យប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវជ្រើសរើសប្រភេទ នៃបណ្តឹងឧបាស្រ័យឱ្យបានត្រឹមត្រូវដោយស្របទៅតាមប្រភេទនៃសេចក្តីសម្រេចដើម។

## ផ្នែកទី ១៖ បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូង។ តុលាការដែលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវបានហៅថា តុលាការនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ហើយការជំនុំជម្រះដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវហៅថា **ការជំនុំជម្រះលើកទី ២** ប៉ុន្តែក្នុងករណីមួយចំនួនតាមបញ្ញត្តិពិសេសដូចជាសេចក្តីសម្រេចរបស់គណៈមេធាវីជាអាទិ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ជាតុលាការនៃការជំនុំជម្រះលើកទី ១ ដែរ។ ដូច្នេះហើយ បណ្តឹងឧទ្ធរណ៍អាចនឹងធ្វើឡើងបានតែចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ចំពោះសាលក្រមរបៀប មិនអាចប្តឹងឧទ្ធរណ៍ឯករាជ្យដោយឯកឯងបានឡើយ។

### ១. របៀបធ្វើបណ្តឹងឧទ្ធរណ៍

ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ប្តឹងទៅតុលាការដើម (តុលាការនៃការជំនុំជម្រះលើកទី ១ ឬសាលាដំបូង)។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីអត្តសញ្ញាណរបស់ភាគី សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ សេចក្តីដែលប្តឹងចំពោះសាលក្រមនោះ និងមូលហេតុទាមទារឱ្យមានការលុបចោល ឬផ្លាស់ប្តូរសាលក្រម។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ក្រៅពីឈ្មោះ និងអាសយដ្ឋានរបស់ភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ភាគី

[4] មាត្រា ២៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ត្រូវសរសេរនូវសញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១ និងសេចក្តីដែលប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ។ ជាទូទៅបណ្តឹងតែងតែមានការទាមទារដែលជាកម្មវត្ថុនៃបណ្តឹង ហេតុនេះបណ្តឹងឧទ្ធរណ៍ភាគីនៃបណ្តឹងត្រូវសរសេរជាចាំបាច់ នូវមូលហេតុដែលទាមទារអោយលុបចោល ឬផ្លាស់ប្តូរនូវសាលក្រមនោះ។[5]

ជាទូទៅការសរសេរ និងការពិចារណាពិតជាមិនបានត្រឹមត្រូវទាំងស្រុងនោះទេ គឺតែងតែមានចំណុចខ្លះមានការខ្វះខាត ពីព្រោះប្រទេសកម្ពុជាមិនសូវសម្បូរនូវធនធានមនុស្ស នោះពាក្យបណ្តឹងខ្លះធ្វើអោយមនុស្សសាមញ្ញ ដែលមិនសូវយល់ដឹងច្បាស់អំពីបញ្ហាផ្លូវច្បាប់ ពេលខ្លះពួកគាត់មិនបានបញ្ជាក់អោយច្បាស់លាស់អំពីមូលហេតុទាមទារអោយលុបចោល ឬផ្លាស់ប្តូរនូវការជំនុំជម្រះលើកទី ១។ តែទោះជាយ៉ាងណាក៏ដោយ ក៏ច្បាប់ទុកសិទ្ធិអោយភាគីដើមបណ្តឹង អាចសរសេរលិខិតជាលាយលក្ខណ៍អក្សរពីចំណុចអំពីការទាមទារនោះ ទៅកាន់តុលាការពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ។[6] ចំពោះចំណុចខាងលើនេះ គឺក្នុងករណីដែលដើមបណ្តឹង ដឹងថាខ្លួនមិនបានសរសេរនូវការទាមទារនៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

ផ្ទុយទៅវិញ បើតុលាការពិនិត្យពាក្យបណ្តឹងនោះឃើញថា មានចំណុចខ្វះខាត តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងបង្គាប់អោយភាគីកែតម្រូវចំណុចនោះ ដោយទុកនូវរយៈពេលសមស្របមួយ។[7] ប៉ុន្តែ បើភាគីដើមបណ្តឹងមិនព្រមកែតម្រូវទេនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវច្រានចោលពាក្យបណ្តឹងនោះដោយដីកាសម្រេច។[8] ចំណុចនេះនឹងត្រូវយកមកអនុវត្តន៍ផងដែរចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍មិនទាន់បានបង់តាមច្បាប់កំណត់។

ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបញ្ជូនទៅចុងចម្លើយបណ្តឹងឧទ្ធរណ៍។ តែបើក្នុងករណីមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ទៅចុងបណ្តឹងឧទ្ធរណ៍បានទេនោះ ត្រូវអនុលោមតាមករណីដែលពាក្យបណ្តឹងមិនត្រឹមត្រូវទៅតាមទម្រង់ច្បាប់។[9]

ម្យ៉ាងវិញទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ ចេញសាលក្រមកំបាំងមុខ ទោះបីលក្ខខណ្ឌចំពោះសាលក្រមកំបាំងមុខ ត្រូវបានបំពេញក៏ដោយ ក៏ភាគីអាចលះបង់ផល

[5] មាត្រា ២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[6] មាត្រា ២៦៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[7] មាត្រា ២៦៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[8] មាត្រា ២៦៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[9] មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ប្រយោជន៍ក្នុងការបន្តនីតិវិធីវិនិច្ឆ័យនៅតុលាការថ្នាក់ដដែល ដោយដាក់ពាក្យបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយក៏អាចធ្វើបណ្ដឹងឧទ្ធរណ៍បានដែរ ដោយរងចាំការផុតរយៈពេលការប្ដឹងទាស់សិន។

### ១.១. សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍

សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ គឺកើតឡើងដោយសារការមិនពេញចិត្តនូវសាលក្រមរបស់សាលាដំបូង។ ដើមចោទ ឬចុងចម្លើយដែលបានបាត់បង់ផលប្រយោជន៍ដោយសារតែសាលក្រមនៃការជំនុំជម្រះលើកទី ១ មានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍។ ការដែលបានបាត់បង់នូវផលប្រយោជន៍នោះ ត្រូវហៅថា មានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ។ ជាគោលការណ៍ បើយកខ្លឹមសារនៃសាលក្រមដែលដើមចោទ ឬចុងចម្លើយនៃការជំនុំជម្រះលើកទី ១ មកប្រៀបធៀបជាមួយនឹងសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយក្នុងករណីដែលសាលក្រមនោះ មានទំហំតូចជាងការទាមទាររបស់ភាគីនោះ ទើបផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ ត្រូវបានទទួលស្គាល់។ ហេតុដូច្នេះជាគោលការណ៍ ភាគីដែលឈ្នះក្ដីទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី ១ គ្មានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យមានន័យថា គ្មានសិទ្ធិប្ដឹងឧទ្ធរណ៍ទេ។ ប្រសិនបើភាគីនោះប្ដឹងឧទ្ធរណ៍ បណ្ដឹងឧទ្ធរណ៍នោះនឹងត្រូវបានលើកចោល ដោយសារបណ្ដឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់។ សិទ្ធិក្នុងការធ្វើប្ដឹងឧទ្ធរណ៍ អាចកើតឡើងចំពោះភាគីដែលបានបាត់បង់ផលប្រយោជន៍ ពីការជំនុំជម្រះលើកទី ១ តែសិទ្ធិនេះក៏អាចបោះបង់ចោលដែរ។[10]

សិទ្ធិប្ដឹងឧទ្ធរណ៍ មិនអាចកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងជាមុនរវាងភាគីទាំងសងខាង មិនប្ដឹងឧទ្ធរណ៍។ ការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍នេះ មានលក្ខណៈខុសពីការព្រមព្រៀងផ្លោះទៅប្ដឹងសាទុក្ខ គឺបិទសិទ្ធិប្ដឹងសាទុក្ខផងដែរ។ ហេតុដូច្នេះ ប្រសិនបើការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ ត្រូវបានបង្កើតឡើងដោយមានសុពលភាព សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវចូលជាស្ថាពរ នៅពេលដែលប្រកាសសាលក្រមនេះ។

សិទ្ធិប្ដឹងឧទ្ធរណ៍ និងកើតឡើងចំពោះបុគ្គលដែលរៀបរាប់ខាងលើនោះ ដោយការប្រកាសសាលក្រមនៃការជំនុំជម្រះលើកទី ១។ ប៉ុន្តែក្រោយពេលសិទ្ធិប្ដឹងឧទ្ធរណ៍កើតឡើង ភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ អាចលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍បានដែរ។ សិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ អាចកើតបានចំពោះភាគីដែលបានបាត់បង់ផលប្រយោជន៍ពីការជំនុំជម្រះលើកទី ១ តែសិទ្ធិនេះក៏មិនអាច

[10] មាត្រា ២៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

បោះបង់ចោលដែរ ដោយមានការព្រមព្រៀងគ្នាជាលាយលក្ខអក្សរថាមិនប្ដឹងឧទ្ធរណ៍ នោះសាលក្រមនៃការជំនុំជម្រះលើកទី ១ និងចូលជាស្ថាពរ។ ការព្រមព្រៀងគ្នាថា មិនប្ដឹងឧទ្ធរណ៍ជាលាយលក្ខអក្សរ គឺខុសគ្នាពីការព្រមព្រៀងគ្នាថាផ្លោះទៅប្ដឹងសាទុក្ខ ពីព្រោះការព្រមព្រៀងគ្នាបែបនេះគឺខុសគ្នាអំពីសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនទាន់ចូលជាស្ថាពរទេ ទោះជាហួសរយៈពេលប្ដឹងក៏ដោយ។ ការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងតាមសេចក្ដីថ្លែងការណ៍។ តែបើភាគីលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ ក្រោយពេលដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ សេចក្ដីថ្លែងការណ៍ស្ដីពីការបោះបង់សិទ្ធិឧទ្ធរណ៍ និងការដកពាក្យបណ្ដឹងត្រូវធ្វើជាមួយគ្នា។[11]

### ១.២. មូលហេតុនៃបណ្ដឹងឧទ្ធរណ៍

ការប្ដឹងទៅសាលាឧទ្ធរណ៍ គឺដោយសារតែភាគីណាមួយមិនសុខចិត្តនឹងសេក្ដីសម្រេចរបស់សាលាដំបូងនូវផ្នែកណាមួយ ឬទាំងអស់ដែលអាចជា សាលក្រម និងជាដីកាសម្រេច ឬអាចនិយាយបានម្យ៉ាងទៀតថា គឺភាគីមិនពេញចិត្តនឹងសេចក្ដីសម្រេចនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូង ដែលជាមូលហេតុធ្វើឱ្យភាគីមានបំណងចង់ធ្វើបណ្ដឹងទៅតុលាការជាន់ខ្ពស់ គឺដើម្បីទទួលបាននូវសេចក្ដីសម្រេចថ្មី ហើយពេញចិត្ត។

### ១.៣. អំឡុងពេលក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ ខែ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូនលិខិតសាលក្រម នៃការជំនុំជម្រះលើកទី ១ ឬពីថ្ងៃដែលដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ ចំពោះសាលក្រមកំបាំងមុខ ប្រសិនបើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ ត្រូវគណនា ដោយគិតពីថ្ងៃដែលទទួលនូវការបញ្ជូននៃលិខិតសាលក្រមកំបាំងមុខ ក្នុងករណីដែលភាគីប្ដឹងទាស់ ដោយគិតថាអាចប្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខនោះ តែតុលាការលើកចោល ឬច្រានចោលពាក្យបណ្ដឹងទាស់ នោះអាចមានករណីមិនអាចប្ដឹងឧទ្ធរណ៍បាន ដោយសារអំឡុងពេល ០១ ខែ បានកន្លងផុតហួសដោយគិតពីថ្ងៃដែលទទួលបាននូវការបញ្ជូននៃលិខិតសាលាក្រមកំបាំងមុខនោះ។ ហេតុដូច្នេះ អំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ ត្រូវគណនា ដោយគិតពីថ្ងៃដែលទទួលការជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវពាក្យបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ។ អំឡុងពេលនេះមិនអាចពន្យារពេលបានទេ ប៉ុន្តែបើភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ មិនអាចប្ដឹងឧទ្ធរណ៍បាន ដោយ

[11] មាត្រា ២៦៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

មូលហេតុមិនមែនជាកំហុសរបស់ភាគីនោះ អាចបំពេញនូវសកម្មភាព ក្រោយបានអំឡុងពេល ០១ សប្តាហ៍បន្ទាប់ពីមូលហេតុនោះបានរលត់។ ដោយឡែកក្រោយសាលក្រម នៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាស ទោះបីជាមិនទាន់ទទួលការបញ្ជូនក៏ដោយ ឬមុនថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលចំពោះបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ឬភាគីដែលមានសិទ្ធិប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ឬភាគីដែលមានសិទ្ធិប្តឹងទាស់ លះបង់សិទ្ធិប្តឹងទាស់ក៏អាចធ្វើបណ្តឹងឧទ្ធរណ៍ មុនអំឡុងពេលនៃការប្តឹងឧទ្ធរណ៍ដែរ។ ទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានផុតរលត់ហើយក៏ដោយ ក៏ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍បានដែរបណ្តឹងឧទ្ធរណ៍នេះហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺការធ្វើឧបាស្រ័យដោយភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀតចំពោះចំណុច មិនបានប្តឹងឧទ្ធរណ៍ដោយខ្លួនឯង។

ប៉ុន្តែ ទោះបីជាមានករណីដូចខាងលើក៏ដោយ ក៏ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ នៅតែអាចមានសិទ្ធិប្តឹងឧទ្ធរណ៍បាន ដោយគ្រាន់តែដាក់ពាក្យបណ្តឹងដូចបណ្តឹងឧទ្ធរណ៍ធម្មតា ក្នុងរយៈពេល ០១ សប្តាហ៍ គិតពីថ្ងៃដែលមូលហេតុដែលធ្វើឱ្យខកខាននោះបានរលត់ ហើយមូលហេតុនោះពុំមែនជាកំហុសរបស់ភាគីនោះទេ។ ជាងនេះទៅទៀតភាគីក៏ត្រូវតែបញ្ជាក់ និងអះអាងអំពីមូលហេតុ និងភស្តុតាងដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ឱ្យបានច្បាស់លាស់។

### ២. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ឱ្យបានទាន់ពេលវេលា គឺមានអានុភាពទៅលើសាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) ដែលអាចបង្អាក់នូវការចូលជាស្ថាពរនៅសាលក្រមនោះ។ ហើយដំណើរការនៃការជម្រះក្តីនៅតុលាការដើមត្រូវបានផ្ទេរមកអោយតុលាការ នៃបណ្តឹងឧទ្ធរណ៍ ដែលគេអោយឈ្មោះថា "អានុភាពនៃការជម្រះក្តីដោយឧទ្ធរណ៍" ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យនៃការទាមទារនោះ។

ចំពោះអានុភាពទាំងពីរខាងលើ គឺមានការប៉ះពាល់ដល់ផលប្រយោជន៍ដល់ភាគី នៃការជម្រះក្តីលើកទី ១ (សាលក្រម) ដោយហេតុថាការធ្វើបណ្តឹងឧបាស្រ័យ។ ជួនកាលភាគីដែលធ្វើបណ្តឹងឧទ្ធរណ៍មិនសុខចិត្តលើសាលក្រមទាំងមូលតែម្តង ក៏ប៉ុន្តែពេលខ្លះប្តឹងមិនសុខចិត្តលើផ្នែកណាមួយនៃសាលក្រមប៉ុណ្ណោះដែលធ្វើអោយចំណុចដែលឯកភាពគ្នា ហើយនោះមិនមានអានុភាពក្នុងការអនុវត្តសាលក្រមឡើយ (អានុភាពបង្អាក់នៅការចូលជាស្ថាពរនៃបណ្តឹងឧទ្ធរណ៍)។

នេះជាអវិភាគនៃបណ្តឹងឧទ្ធរណ៍ ប៉ុន្តែភាគីចុងចម្លើយបណ្តឹងឧទ្ធរណ៍ មិនបានធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនៅផ្នែកមួយចំនួន ក្រៅពីផ្នែកនៃការធ្វើបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងនៃបណ្តឹងឧទ្ធរណ៍ អាចសុំដាក់ពាក្យនៅផ្នែកដែលមិនបានប្តឹងឧទ្ធរណ៍ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ដែលសម្រេចដោយសាលក្រមដើមបាន[12] បើដូចនេះទោះបីជាសាលក្រមនោះ មិនទាន់ចូលជាស្ថាពរក៏ដោយ ក៏អាចអនុវត្តបានដែរ។

លើសពីនេះទៅទៀត ក្នុងចំណោមសាលក្រមដើម ចំពោះផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍មិនបានធ្វើឧបាស្រ័យ គឺភាគីមិនចាំបាច់ធ្វើការទាញហេតុផលឡើយ[13] ហើយតុលាការមិនអាចធ្វើការផ្លាស់ប្តូរការវិនិច្ឆ័យអំពីផ្នែកនោះបានដែរនៅក្នុងសាលក្រមដើម។[14] ប៉ុន្តែនៅក្នុងការវិនិច្ឆ័យអំពីផ្នែកនោះ នៅក្នុងសាលក្រមដើម មិនចូលជាស្ថាពរឯកឯងទេ។ តែបើមានការព្រមព្រៀងគ្នាថាមិនប្តឹងឧទ្ធរណ៍ ចំពោះផ្នែកណាមួយនូវការទាមទារ ឬភាគីសងខាងលះបង់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងសិទ្ធិប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ចំពោះផ្នែកណាមួយនៃការទាមទារនោះ ផ្នែកនោះនៃសាលក្រមដើមត្រូវចូលជាស្ថាពរ។

## ៣. អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

នៅពេលដែលភាគីធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមនៃសាលាដំបូង បណ្តឹងឧទ្ធរណ៍នោះរមែងមានអានុភាពទៅលើសាលក្រមដូចជា អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម អានុភាពនៃការផ្ទេរការជម្រះក្តី និងភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ដែលនឹងត្រូវរៀបរាប់ដូចចំណុចខាងក្រោមនេះ។

### ៣.១. អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម

នៅពេលដែលភាគីបានធ្វើបណ្តឹងឧទ្ធរណ៍នៅក្នុងអំឡុងពេលដែលបានកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍ទោះជាអំឡុងពេលដែលបានកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍នោះបានផុតរយៈពេលហើយក៏ដោយ ក៏សាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) មិនចូលជាស្ថាពរដែរ។ នេះគេហៅថា "**អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃបណ្តឹងឧទ្ធរណ៍**"។ មិនតែប៉ុណ្ណោះអានុភាពអនុវត្តសាលក្រមក៏មិនអាចកើតមានដែរ ប្រសិនបើសាលក្រមដើមនោះ ពុំមានភ្ជាប់ជាមួយការអនុវត្តជាបណ្តោះ

[12] មាត្រា ២៧៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[13] មាត្រា ២៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[14] មាត្រា ២៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

អាសន្ន ឬអាជ្ញាអស់ជំនុំពុំទាន់កើតឡើង ដែលមានចែងនៅក្នុងមាត្រា ១៩៥ និងមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ៣.២. អានុភាពនៃការផ្ទេរការជម្រះក្តី

ពេលដែលមានបណ្តឹងឧទ្ធរណ៍កើតឡើងការចាត់ការនៃ ការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ នេះគេហៅថា "**អានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍**"។ ដោយសារអានុភាពនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីការទាមទារនោះ។

### ៣.៣. អវិភាគនៃបណ្តឹងឧទ្ធរណ៍

អានុភាពទាំងពីរខាងលើនេះអាចមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃកាជម្រះក្តីលើកទី ១ គឺក្នុងករណីដែលភាគីប្តឹងមិនសុខចិត្តលើផ្នែកណាមួយនៃសាលក្រម ក៏ប៉ុន្តែការធ្វើបណ្តឹងឧទ្ធរណ៍ នឹងធ្វើឱ្យចំណុចទាំងអស់ ព្រមទាំងធ្វើឱ្យចំណុច ដែលបានឯកភាពនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនមានអានុភាពអនុវត្តឡើយ (អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម)។ ថ្វីបើដើមបណ្តឹងឧទ្ធរណ៍ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយក៏ "**អានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម**" និង "**អានុភាពនៃការផ្ទេរការជម្រះក្តី**" កើតមានឡើងចំពោះការទាមទារទាំងអស់ដែលបានសម្រេចនៅក្នុងសាលក្រមដើមដែរ។ គេហៅថា "**ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍**"។ ដូច្នេះហើយ នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ ដោយហេតុថាសាលក្រមដើមត្រូវបានរារាំង នូវអានុភាពចូលជាស្ថាពរ ហើយសូម្បីតែផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់ចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចនឹងធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដើមបានទេ ប្រសិនបើមានការប្រកាសឱ្យធ្វើការអនុវត្តជាបណ្តោះអាសន្នទៅលើផ្នែកដែលខ្លួនឈ្នះនៅក្នុងសាលក្រមនោះ។

ម្យ៉ាងវិញទៀតនៅក្នុងសាលក្រមដើម ចំពោះផ្នែកដែលបណ្តឹងឧទ្ធរណ៍មិនបានធ្វើបណ្តឹងឧទ្ធរណ៍ ភាគីមិនចាំបាច់ធ្វើការទាញហេតុផលឡើយ។ លើសពីនេះទៅតុលាការពុំចាំបាច់ធ្វើការផ្លាស់ប្តូរការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើមបានដែរ ប៉ុន្តែការវិនិច្ឆ័យអំពីផ្នែកនោះក៏មិនត្រូវចូលជាស្ថាពរដោយឯកឯងបានដែរ។ ហើយចំពោះផ្នែកណាមួយចំពោះការទាមទារនៃសាលក្រមដើមនឹងត្រូវចូលជាស្ថាពរបើសិនជាភាគី មានការព្រមព្រៀងគ្នាថាមិនប្តឹងឧទ្ធរណ៍ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ និងសិទ្ធិប្តឹងឧទ្ធរណ៍បន្ទាប់បន្សំក្នុងផ្នែកនេះ។

## ៤. ការជំនុំជម្រះរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍

ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមដើម ហើយដើម្បីចេញសាលដីកាដែលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើត្រឹមតែ ក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ។[15] នៅក្នុងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ គឺជាការបន្តការ វិនិច្ឆ័យដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលបានបញ្ចប់ម្តងនៅក្នុង ការជំនុំជម្រះលើកទី ១ ដូចនេះសកម្មភាពបណ្តឹង (ពាក្យសុំការអះអាងអង្គហេតុ ការស្នើសុំឱ្យពិនិត្យភស្តុតាង ការសារភាពជាអាទ៍) ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែរ។[16] ម្យ៉ាងវិញទៀត នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីត្រូវបានផ្តល់ឪកាសឱ្យដាក់មធ្យោបាយតទល់ ឬការពារខ្លួនបាន ដែលមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី ១ ប៉ុន្តែការទទួលស្គាល់ការមធ្យោបាយតទល់ ឬការពារខ្លួនបានលុះត្រាតែមិនផ្ទុយនឹងមាត្រា ១០៨ និងមាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[17]

តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាចុងក្រោយចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ក្នុងករណី បណ្តឹងឧទ្ធរណ៍នោះមិនស្របច្បាប់ ហើយចំណុចដែលខ្វះខាតមិនអាចកែតម្រូវបាន (ហួសអំឡុងពេលប្តឹងឧទ្ធរណ៍) តុលាការអាចលើកបណ្តឹងឧទ្ធរណ៍ចោលដោយសាលដីកា ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ហៅថា សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍។[18] ក្នុងករណីតុលាការយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ តុលាការត្រូវចេញសាលដីកាច្រានចោល បណ្តឹងឧទ្ធរណ៍ទោះបីជាសំអាងហេតុនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ បើយល់ឃើញថាសេចក្តីបញ្ចប់នៃសាលក្រមនោះត្រឹមត្រូវផ្អែកលើសំអាងហេតុផ្សេងទៀតហៅថា **សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍។**[19]

---

[15] មាត្រា ២៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[16] មាត្រា ២៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[17] មាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[18] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[19] មាត្រា ២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

ផ្ទុយទៅវិញ បើតុលាការយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬ នីតិវិធីនៃការជំនុំជម្រះលើកទី ១ ខុសច្បាប់ធ្ងន់ធ្ងរតុលាការត្រូវទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១។[20] ក្នុងករណីតុលាការលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ជាគោលការណ៍តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើការ វិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ហើយករណីនេះ សេចក្តីសម្រេចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍មានរូបភាពពីរ គឺ **លុបចោលសាលក្រមដើម ច្រានចោលការទាមទាររបស់ដើមចោទ** និង**កែប្រែផ្លាស់ប្តូរសាលក្រមដើម**។[21] ប៉ុន្តែក្នុងករណីតុលាការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកបណ្តឹងចោលដោយសារបណ្តឹងខុសច្បាប់ ជាគោលការណ៍តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបញ្ជូនរឿងក្តីនោះត្រលប់ទៅសាលាដំបូងវិញ លើកលែងយល់ឃើញថាគ្មានភាពចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្តីនោះ។[22] ក្រៅពីករណីនេះហើយតុលាការនៃបណ្តឹងឧទ្ធរណ៍ អាចបញ្ជូនរឿងក្តីត្រលប់ទៅសាលាដំបូងវិញបានក្នុងករណីយល់ថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្តីនោះ (ករណីមិនបានវិនិច្ឆ័យអំពីចំនួនទឹកប្រាក់នៃការទាមទារជាអាទិ៍)។ [23] ម្យ៉ាងវិញទៀតក្នុងករណីនីតិវិធីបណ្តឹងនៅសាលាដំបូងផ្ទុយច្បាប់តុលាការអាចបញ្ជូនរឿងក្តីត្រលប់ទៅវិញ ពេលនោះនីតិវិធីនៃបណ្តឹងដែលផ្ទុយច្បាប់នោះ ត្រូវបានលុបចោលដោយស្វ័យប្រវត្តិ។[24]

### ៥. ការដកបណ្តឹងឧទ្ធរណ៍

ពាក្យបណ្តឹងអាចដកវិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានចេញ។ មិនថាបណ្តឹងរដ្ឋប្បវេណីប្រភេទណាមួយឡើយ ដើមបណ្តឹងអាចដកវិញបាន។ ចំពោះបណ្តឹងរដ្ឋប្បវេណីមិនថាប្រភេទបណ្តឹងណាមួយទេ គឺដើមបណ្តឹងអាចដកពាក្យបណ្តឹងវិញបាន។ យ៉ាងណាមិញបណ្តឹងឧទ្ធរណ៍ក៏អញ្ចឹងដែរ ភាគីនៃដើមបណ្តឹងឧទ្ធរណ៍អាចដកពាក្យបណ្តឹងវិញបានរហូតដល់ពេលសាលដីកាចុងក្រោយរបស់ តុលាការនៃបណ្តឹងឧទ្ធរណ៍បានប្រកាស។[25] ការដកបណ្តឹងឧទ្ធរណ៍នេះ គឺការដកនូវសេចក្តីឧបាស្រ័យទៅលើសាលក្រមនៃការជំនុំ

[20] មាត្រា ២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[21] មាត្រា ២៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[22] មាត្រា ២៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[23] មាត្រា ២២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[24] មាត្រា ២៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

[25] មាត្រា ២៦៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ជម្រះលើកទី ១ ហើយដោយសារមូលហេតុដកពាក្យបណ្តឹងឧទ្ធរណ៍នេះ នីតិវិធីនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបញ្ចប់។ ការដកពាក្យបណ្តឹងឧទ្ធរណ៍នេះពុំប៉ះពាល់ដល់ អានុភាពលើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ឡើយ។

ការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺត្រូវបានចាត់ទុកថាមិនបានចាត់ការនៅតុលាការនៃបណ្តឹងឧទ្ធរណ៍តាំងពីដំបូង។[26] អានុភាពនៃការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺធ្វើឱ្យសាលក្រមនៃការជំនុំជម្រះលើកទី ១ និងចូលជាស្ថាពរទោះជាការហួសអំឡុងពេលសម្រាប់បណ្តឹងឧទ្ធរណ៍ ឬមិនទាន់ហួសក៏ដោយ។ ការដកពាក្យបណ្តឹងនេះ គឺមិនចាំបាច់មានការយល់ព្រមពីចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍ឡើយពីព្រោះគ្មានផលប្រយោជន៍។

### ៦. បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាបណ្តឹងដែលចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍អាចដាក់អមជាមួយនឹងបណ្តឹងឧទ្ធរណ៍ ដើម្បីទាមទារផលប្រយោជន៍ដែលខ្លួនបានបាត់បង់ក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១។ ចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍អាចប្រើយន្តការនេះ ដើម្បីធ្វើបណ្តឹងឧបាស្រ័យទាមទារឱ្យផ្លាស់ប្តូរនូវផ្នែកនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលខ្លួនបានបាត់បង់ផលប្រយោជន៍។

ដូចដែលបានពន្យល់មកហើយ នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ ការទាមទារទាំងត្រូវបានវិនិច្ឆ័យដោយសាលក្រមនៃការជុំនំជម្រះក្តីលើកទី ១ ដែលត្រូវបានប្តឹងឧបាស្រ័យត្រូវផ្ទេរទៅឱ្យតុលាការនៃបណ្តឹងឧទ្ធរណ៍ (ភាពអវិភាគនៃអានុភាពនៃការផ្ទេរការជម្រះក្តី)។ ដូច្នេះហើយចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍អាចឆ្លៀតឱកាសនេះ ដើម្បីធ្វើបណ្តឹងឧបាស្រ័យទាមទារឱ្យផ្លាស់ប្តូរនូវភាគនៃសាលក្រមនៃការជុំនំជម្រះលើកទី ១ ដែលខ្លួនបានបាត់បង់នូវផលប្រយោជន៍ឱ្យបានទទួលនូវផលប្រយោជន៍នោះវិញ។ នេះគេហៅថា **បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ**។ នេះជាយន្តការមួយការពារភាគីម្ខាងទៀត ពីការខាតបង់ផលប្រយោជន៍ពីស្ថានភាពនៃសាលក្រមនៃការ ជុំនំជម្រះលើកទី ១ បានទទួលស្គាល់នូវការទាមទារមួយភាគ ឬច្រានចោលនូវការទាមទារមួយភាគរបស់ដើមបណ្តឹង ហើយប្រសិនបើភាគីមួយទៀតគិតឃើញថា បើភាគីម្ខាងទៀតស្កប់ចិត្តនឹងសាលក្រមនោះខ្លួនក៏មិនប្តឹងឧទ្ធរណ៍ដែរ។ តាមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ទំហំនៃឧបាស្រ័យដែលត្រូវបានវិនិច្ឆ័យនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានពង្រីក។ មានន័យថាតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវវិនិច្ឆ័យ

[26] មាត្រា ២៦៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

មិនមែនតែអំពីភាពត្រឹមត្រូវ នៃបណ្ដឹងឧបាស្រ័យរបស់ដើមបណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះទេ គឺវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឧបាស្រ័យរបស់ចុងចម្លើយបណ្ដឹងឧទ្ធរណ៍ផងដែរ។ ប្រសិនបើមានតែដើមបណ្ដឹងឧទ្ធរណ៍ទេដែលធ្វើ ឧបាស្រ័យទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍មិនអាចផ្លាស់ប្ដូរសាលក្រមដើម ដោយខូចប្រយោជន៍ចំពោះដើមបណ្ដឹងឧទ្ធរណ៍ ដោយហួសទំហំនៃសាលក្រមដើមបានឡើយ ប៉ុន្តែប្រសិនបើមានបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំពីចុងចម្លើយឧទ្ធរណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចធ្វើការផ្លាស់ប្ដូរយ៉ាងនេះបាន។ ប៉ុន្តែបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាការធ្វើបណ្ដឹងឧបាស្រ័យដោយភ្ជាប់ជាមួយនិងបណ្ដឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀត ចំពោះចំណុចដែល ភាគីនៅមិនបានប្ដឹងឧទ្ធរណ៍ដោយខ្លួនឯង។ នៅត្រង់កន្លែងនេះ ប្រសិនបើបណ្ដឹងដែលជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះគ្មានទេវាក៏និងអស់អានុភាពដែរ។ តែប្រសិនបើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះត្រូវប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះត្រូវជាបណ្ដឹងឧទ្ធរណ៍ដែលឯករាជ្យវិញ។

បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំអាចធ្វើបានតែមុនពេលដែលការទាញហេតុផលដោយផ្ទាល់មាត់នៃការជុំនំជម្រះបណ្ដឹងត្រូវបានបញ្ចប់។ ទោះបីជាចុងចម្លើយនៃបណ្ដឹងឧទ្ធរណ៍បានលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ក៏ដោយ ក៏ចុងចម្លើយនៃបណ្ដឹងឧទ្ធរណ៍នោះអាចធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។ របៀបធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ត្រូវអនុលោមតាមបញ្ញត្តិនៃបណ្ដឹងឧទ្ធរណ៍។

### ៧. ការវិនិច្ឆ័យ និងការចេញសាលដីកា

ក្រោយពីបានធ្វើ និងដាក់បណ្ដឹងហើយ នីតិវិធីបន្ទាប់ គឺនីតិវិធីដែលតុលាការទទួលបណ្ដឹងត្រូវវិនិច្ឆ័យ និងចេញដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដែលនឹងរៀបរាប់ដូចខាងក្រោមនេះ។

#### ៧.១. នីតិវិធីជម្រះលើបណ្ដឹងឧទ្ធរណ៍

ការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យរកភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវនៃបណ្ដឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយជាមួយគ្នានេះដែរត្រូវពិនិត្យឡើងវិញ លើអង្គហេតុ និងអង្គច្បាប់ចំពោះការទាមទារនៃការជំនុំជម្រះលើកទី ១ ទៅតាមទំហំដែលចាំបាច់ ដើម្បីវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការប្ដឹងឧបាស្រ័យនោះ។ ប៉ុន្តែតុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងមិនចាត់ការរឿងក្ដីសារឡើងវិញទាំងស្រុងតាំងពីដំបូងមក ដោយមិនគិតដល់ការជំនុំជម្រះលើកទី ១ នោះទេ។ ទោះជាយ៉ាងណាក្ដី តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងបន្តការជំនុំជម្រះនេះដោយផ្អែកលើធនធាន ដែលបានប្រមូលនៅក្នុងការជំនុំជម្រះលើកទី ១ និងបន្ថែមនូវធនធានថ្មី

ផ្សេងទៀត ហើយបន្ទាប់មកនឹងធ្វើការវិនិច្ឆ័យ តើគួររក្សាទុកនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានឬទេ?

នៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមដើម ហើយទំហំឧបាស្រ័យនោះ ត្រូវបានកំណត់ដោយបណ្តឹងរបស់ដើមបណ្តឹងឧទ្ធរណ៍ និងចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍។ ឧបាស្រ័យដែលជាកម្មវត្ថុនៃការវិនិច្ឆ័យគឺ ជាការឧបាស្រ័យចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១។ នៅក្នុងបណ្តឹងឧទ្ធរណ៍ គឺភាគីមានសិទ្ធអាចធ្វើឧបាស្រ័យចំពោះសេចក្តីសម្រេចអំពីចំណុចដែលជាបុរេលក្ខខណ្ឌសម្រាប់សាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ ឬចំណុចដែលទាក់ទងនឹងនីតិវិធី ឬដីកាសម្រេចមិនអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមកម្មវត្ថុបណ្តឹងបានផងដែរ[27] ប៉ុន្តែចំណុចទាំងនេះគ្រាន់តែត្រូវបានវិនិច្ឆ័យក្នុងនាមជាមូលដ្ឋាន នៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមចុងក្រោយប៉ុណ្ណោះ។

ដោយសារកម្មវត្ថុចម្បងនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧទ្ធរណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ គឺធ្វើត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនៅសាលក្រមដើមនៃការជំនុំជម្រះលើកទី ១ ប៉ុណ្ណោះ។[28] ប៉ុន្តែនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចៅក្រមត្រូវផ្លាស់ប្តូរពីចៅក្រមជំនុំជម្រះលើកទី ១ ហេតុនេះហើយភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផល នៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១។ លើសពីនេះទៅទៀត ដោយសារនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចៅក្រមត្រូវផ្លាស់ប្តូរពីចៅក្រមនៃការជំនុំជម្រះលើកទី ១។ ហេតុដូច្នេះ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះលើកទី ១។ នៅក្នុងការជម្រះបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យ ដោយបើកឡើងនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ម្តងរួចមកហើយនៅក្នុងការជំនុំជម្រះលើកទី ១។

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីត្រូវបានផ្តល់ឱកាសដើម្បីដាក់មធ្យោបាយតទល់ ឬការពារខ្លួនដោយគ្មានកម្រិតទេនោះ មានការបារម្ភណ៍ថា បណ្តាលឱ្យមានការយឺតយ៉ាវចំពោះនីតិវិធីដោយសារភាគីមិនខិតខំប្រឹងប្រែងធ្វើការទាញហេតុផល នៅក្នុងការជំនុំជម្រះលើកទី ១

[27] មាត្រា ៨៤ កថាខណ្ឌទី៤ និងមាត្រា ២៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[28] មាត្រា ២៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។៧

ដោយមើលស្រាលចំពោះនីតិវិធី នៃការជំនុំជម្រះលើកទី ១ តែបែរជាយកចិត្តទុកដាក់ជាខ្លាំងចំពោះការជំនុំជម្រះបណ្តឹងឧទ្ធរណ៍វិញ។

### ៧.២. ការចេញដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

បន្ទាប់ពីបានវិនិច្ឆ័យបណ្តឹងរួចរាល់ហើយតុលាការត្រូវចេញដីកា នៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដូចជាសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ និងសាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ដែលនឹងត្រូវបកស្រាយដូចខាងក្រោមនេះ។

#### ៧.២.១. សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍

ជាគោលការណ៍ ការវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍ថាត្រឹមត្រូវតាមច្បាប់ ឬមិនត្រឹមត្រូវតាមច្បាប់នោះត្រូវបើកការទាញហេតុផលដោយផ្ទាល់មាត់ [29] ប៉ុន្តែចំពោះបណ្តឹងដែលមិនអាចកែតម្រូវចំណុចខ្វះខាតដូចជាករណីដែលបណ្តឹងឧទ្ធរណ៍នោះបានប្តឹងនៅក្រោយពេលដែលបានកំណត់ឱ្យប្តឹងឧទ្ធរណ៍ជាដើមទោះជាធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ក៏វាមិនអាចទទួលបានផលប្រយោជន៍អ្វីឡើយ។ ហេតុដូច្នេះក្នុងករណីនេះតុលាការអាចលើកចោលបណ្តឹងឧទ្ធរណ៍ដោយចេញសាលដីកា ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ។ តែចំពោះសិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ និងការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ [30] គឺការដែលលើកពាក្យបណ្តឹងឧទ្ធរណ៍ចោលដោយដីកាសម្រេចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។

#### ៧.២.២. សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍

នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មានភាពត្រឹមត្រូវទោះបីជាសំអាងហេតុនៃសាលក្រមនោះមិនត្រឹមត្រូវ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងនោះដោយហេតុថាវា គ្មានមូលហេតុក្នុងការធ្វើបណ្តឹងឧបាស្រ័យចំពោះសាលក្រមទេ[31] ពីព្រោះគ្មានមូលហេតុក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ។

ប្រសិនបើទំហំនៃការទាមទារដែលសុំបានដោយពាក្យបណ្តឹង ឬបណ្តឹងនោះតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំមិនអាចមានទៅលើ សេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម

[29] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[30] មាត្រា ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[31] មាត្រា ២៧៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

នោះទេ។ ហេតុដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនចាំបាច់ធ្វើសាលដីកាដែលរក្សាទុកសេចក្តីសម្រេចបញ្ចប់ នៃការជំនុំជម្រះលើកទី ១ ដោយគ្រាន់តែប្តូរនូវមូលហេតុឡើយ។ ដូចនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ អាចច្រានចោលនូវបណ្តឹងឧទ្ធរណ៍បាន។ ក្នុងករណីដែលមានអានុភាពនៃអាជ្ញាអស់ជំនុំមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រម តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាសនូវសាលដីកាដែលមាន នូវសេចក្តីសម្រេចបញ្ចប់ដូចនឹងសាលក្រមដើមដោយប្តូរនូវសំអាងហេតុ។

ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ តាមមាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ ក៏តុលាការត្រូវច្រានចោលពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះដែរ។

ប្រសិនបើសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ សាលក្រមដើមក៏ត្រូវចូលជាស្ថាពរដែរ។ ក្នុងករណីនេះប្រសិនបើសាលក្រមដើមជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកសាលក្រមដើមក្លាយទៅជាលិខិតអនុវត្ត នេះបើតាមមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៧.២.៣. សាលដីការទទួលស្គាល់បណ្តឹងឧទ្ធរណ៍

ផ្ទុយទៅវិញ ប្រសិនបើការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជុំនំជម្រះលើកទី ១ មានមូលហេតុត្រឹមត្រូវ ហើយសាលក្រមនៃការជុំនំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬប្រសិន បើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ខុសច្បាប់ធ្ងន់ធ្ងរ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយតុលាការត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ។[32] ការលុបចោលនៃការជំនុំជម្រះលើកទី ១ មានន័យថា តុលាការមិនបានឆ្លើយតបទៅនឹងបណ្តឹងដែលបានប្តឹងតុលាការត្រូវចាត់វិធានការសមរម្យដូចខាងក្រោមនេះ៖

#### ៧.២.៣.១. ការលុបចោល និងការជំនុំជម្រះដោយខ្លួនឯង

ដោយសារការជំនុំជម្រះបណ្តឹង គឺជាការវិនិច្ឆ័យលើអង្គហេតុ ជាគោលការណ៍ទោះប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមរបស់សាលាដំបូង តុលាការនៃបណ្តឹងនោះត្រូវវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍នោះជំនួសសាលាដំបូង។

[32] មាត្រា ២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

នៅក្នុងករណីនេះសេចក្តីបញ្ចប់នូវការវិនិច្ឆ័យមាន ពីរយ៉ាងគឺៈ

- ការលុបចោលសាលក្រមដើម និងការច្រានចោលការទាមទាររបស់ដើមចោទ
- កែប្រែ ឬផ្លាស់ប្តូរសាលក្រមដើម ដោយបញ្ចូលគ្នានូវការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង។

### ៧.២.៣.២. ការលុបចោល និងការបញ្ជូនត្រលប់មកវិញ

ក្នុងករណីដែលតុលាការដែលទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយលុបនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលុបចោលបណ្តឹង ហើយយល់ឃើញថាបណ្តឹងមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបញ្ជូនរឿងក្តីទៅសាលាដំបូងវិញ ពីព្រោះការវិនិច្ឆ័យអំពីអង្គសេចក្តីមិនបានធ្វើឡើងដោយតុលាការ នៃការជំនុំជម្រះលើកទី ១។ ប៉ុន្តែនៅក្នុងករណីដែលសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹងដោយខ្វះខាតលក្ខខណ្ឌនៃបណ្តឹងនោះអាចមានករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានវិនិច្ឆ័យទៅលើអង្គហេតុពុំបានគ្រប់គ្រាន់ទេ ដូច្នេះ ដើម្បីរក្សាផលប្រយោជន៍របស់ភាគីនៅដំណាក់កាលវិនិច្ឆ័យពោលគឺ ដើម្បីធានាទៅលើឱកាស ដែលអាចធ្វើនីតិវិធីបាន ២ ដង ក្នុងការវិនិច្ឆ័យរឿងពិត ទម្រាំបានទៅដល់ការវិនិច្ឆ័យនៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍បញ្ជូនត្រលប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញ (សាលាដំបូង) ហើយធ្វើនីតិវិធីនោះសាជាថ្មីឡើងវិញ។ ប៉ុន្តែនៅក្នុងករណីដែលការវិនិច្ឆ័យទៅលើអង្គហេតុនោះគ្រប់គ្រាន់ហើយ ឬក្នុងករណីដែលគូភាគីគ្មានវិវាទនៃអង្គហេតុនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនចាំបាច់បញ្ជូនត្រលប់ទៅវិញទេ។

ចំពោះសាលដីកាបញ្ជូនរឿងក្តីត្រលប់ទៅវិញ អាចប្តឹងសាទុក្ខបាន។ នៅពេលដែលសាលដីកាបញ្ជូនរឿងក្តីត្រលប់ទៅវិញ ចូលជាស្ថាពរ រឿងក្តីនោះត្រូវផ្ទេរទៅតុលាការដើមវិញ (តុលាការនៃការជំនុំជម្រះលើកទី ១)។ បន្ទាប់មក សាលាដំបូងត្រូវបន្តនីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមក។ នីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមកនៅតែមានអានុភាពលើកលែងតែនីតិវិធីនោះ ត្រូវបានយល់ឃើញថា ផ្ទុយនឹងច្បាប់នៅក្នុងសំអាងហេតុដើម្បីលុបចោលសាលក្រមដើម (នៅក្នុងសាលដីកា)។

### ៧.២.៣.៣. ការលុបចោល និងផ្ទេរនូវរឿងក្តី

ក្នុងករណីដែលបានលុបចោលនូវសាលក្រមរបស់សាលាដំបូង ដោយមូលហេតុខុសពីសមត្ថកិច្ចផ្តាច់មុខ របស់តុលាការនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវផ្ទេររឿងក្តីនោះ ទៅតុលាការដែលមានសមត្ថកិច្ចដោយផ្ទាល់វិញ ដោយមិនចាំបាច់បញ្ជូនរឿងក្តីនោះត្រលប់

ទៅតុលាការដើមដែលបានចេញសាលក្រមនៃការជំនុំជម្រះលើកទី ១ វិញទេ។ ទោះបីជាខុសសមត្ថកិច្ចផ្ដាច់មុខក៏ដោយ ក៏ការណ៍នេះមិនមែនក្លាយទៅជាមូលហេតុនៃការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ឡើយ។

## ៨. វិសាលភាពនៃការលុបចោល និង ការផ្លាស់ប្តូរ

តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចលុបចោលបាន ឬការផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានត្រឹមត្រូវនៃឧបាស្រ័យនៃបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ភាគីប៉ុណ្ណោះ។[33] នេះគឺជាការតំណាងចំពោះគោលការណ៍សិទ្ធិចាត់ចែងរបស់ភាគីដែលមានចែងនៅក្នុងមាត្រា ១៨២ កថាខណ្ឌទី ១ និងទី ២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) ក្នុងតុលាការនៃបណ្ដឹងឧទ្ធរណ៍។ ហេតុនេះហើយចំពោះភាគីដែលមិនបានប្ដឹងឧបាស្រ័យទេ ទោះជាសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ ក៏មិនផ្លាស់ប្តូរនូវការវិនិច្ឆ័យបានដែរ ហើយក៏មិនអាចចេញសាលដីកាដែលផ្តល់នូវផលប្រយោជន៍ជាងសាលក្រមនៃការជំនុំជម្រះលើកទី ១ ឱ្យហួសពីទំហំនៃបណ្ដឹងឧបាស្រ័យបានទេ (គោលការណ៍នៃការហាមឃាត់ការផ្លាស់ប្តូរដោយផ្តល់លើប្រយោជន៍)។

ឧទាហរណ៍ ប្រសិនបើចុងចម្លើយដែលបានចាញ់ក្តីចំពោះ បណ្ដឹងដើម និងបណ្ដឹងតបបានប្តឹងឧទ្ធរណ៍ចំពោះតែសាលក្រមនៃបណ្ដឹងតបប៉ុណ្ណោះ ទោះបីជាតុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃបណ្ដឹងដើមមិនមានភាពត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្ដឹងឧទ្ធរណ៍មិនអាចវិនិច្ឆ័យអំពីសាលក្រមនៃបណ្ដឹងដើមបានឡើយ។ ម្យ៉ាងទៀត ប្រសិនបើមិនមានបណ្ដឹងរបស់ភាគីម្ខាងទៀត ឬមិនមានបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ភាគីម្ខាងទៀតទេ ជាគោលការណ៍ដើមបណ្ដឹងឧទ្ធរណ៍ មិនអាចទទួលនូវសាលដីកាដែលខាតបង់ផលប្រយោជន៍ជាងអ្វីដែលបានសម្រេចនៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ បើយ៉ាងច្រើនបំផុត បណ្ដឹងឧទ្ធរណ៍នោះគ្រាន់តែបានច្រានចោលប៉ុណ្ណោះ (គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍)។ ទោះបីជាមានបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំក៏ដោយ ក៏ដើមបណ្ដឹងឧទ្ធរណ៍អាចរួចផុតពីការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍បានដោយការដកពាក្យបណ្ដឹងឧទ្ធរណ៍។

គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយផ្តល់ផលប្រយោជន៍ និងគោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតប្រយោជន៍ ត្រូវអនុវត្តចំពោះតែទំហំដែលតុលាការត្រូវបានចង

[33] មាត្រា ២៨២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដោយពាក្យសុំរបស់ភាគីតែប៉ុណ្ណោះ។[34] ហេតុដូច្នេះ ការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីជាដើម ដែលអាចដោយឆន្ទានុសិទ្ធិរបស់តុលាការមិនត្រឹមត្រូវទទួលឥទ្ធិពលពីពាក្យសុំរបស់ភាគីឡើយ។

## ផ្នែកទី ២៖ បណ្តឹងសាទុក្ខ

### ១. អត្ថន័យនៃបណ្តឹងសាទុក្ខ

#### ១.១. ទស្សនៈនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលទាមទារអោយវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះតែការអនុវត្តច្បាប់ប៉ុណ្ណោះ។ ជាគោលការណ៍ បណ្តឹងសាទុក្ខអាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។[35] ក៏ប៉ុន្តែក្នុងករណីដែលមានការព្រមព្រៀងស្តីពីការប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល និងក្នុងករណីដែលសាលាឧទ្ធរណ៍ ជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្តឹងសាទុក្ខដោយផ្ទាល់បាន ចំពោះសាលក្រម ឬសាលដីកានៃតុលាការជំនុំជម្រះលើកទី ១។[36]

ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាដើមចុងក្រោយ ក្នុងនាមជាតុលាការនៃបណ្តឹងសាទុក្ខ ហេតុដូច្នេះខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតទៅលើសាលក្រម ឬសាលដីកាដើម ដោយផ្អែកទៅលើធនធានដែលត្រូវបានប្រើប្រាស់សម្រាប់ការវិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកានោះ។ តុលាការនៃបណ្តឹងសាទុក្ខ មិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដោយផ្អែកលើការទទួលស្គាល់អង្គហេតុដោយតុលាការដើម។ ក្នុងន័យនេះ ជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរ ដោយស្របច្បាប់ក្នុងសាលក្រម ឬសាលដីកាដើម (មាត្រា ២៩៦ ប៉ុន្តែ ចំពោះចំណុចដែលតុលាការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួនមិនមានអានុភាពចងឡើយ សូមមើលមាត្រា ២៩៧)។

[34] មាត្រា ១៨២ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[35] មាត្រា២៨៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[36] មាត្រា ២៨៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បណ្តឹងសាទុក្ខ គឺជាឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (តុលាការកំពូល) ចំពោះសាលក្រម ឬសាលដីកាចុងក្រោយ។ តុលាការដែលជំនុំជម្រះលើបណ្តឹងសាទុក្ខហៅថា **តុលាការនៃបណ្តឹង សាទុក្ខ** ដែលការជំនុំជម្រះ ហៅថា **ការជំនុំជម្រះលើកចុងក្រោយ**។ តុលាការនៃបណ្តឹងសាទុក្ខ វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះតែអង្គច្បាប់ប៉ុណ្ណោះ។ ពីព្រោះគោលបំណងនៃបណ្តឹងសាទុក្ខ ការពារភាគីដែលទទួលរងភាពខូចខាត ប្រយោជន៍ពីការជំនុំជម្រះដែលមិនត្រឹមត្រូវនឹងធ្វើអោយមានឯកភាពគ្នាចំពោះការបកស្រាយច្បាប់ ប៉ុន្តែភាគីមិនអាចធ្វើបណ្តឹងសាទុក្ខបាន ដោយគ្រាន់តែផ្អែកលើមូលដ្ឋានថាខ្លួនរងការខូចប្រយោជន៍ពី សាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខនោះទេពោលគឺច្បាប់ ឬបទដ្ឋានគតិយុត្តិដែលជះឥទ្ធិពលដល់សាលក្រម ឬសាលដីកានោះ។

### ១.២. គោលបំណងនៃបណ្តឹងសាទុក្ខ

គោលដៅនៃការជំនុំជម្រះបណ្តឹងសាទុក្ខ គឺការពារភាគីដែលបានទទួលរងនូវការខូចខាតប្រយោជន៍ពីការជំនុំជម្រះដែលមិនត្រឹមត្រូវហើយព្រមព្រៀងជាមួយគ្នាមានគោលដៅធ្វើអោយមានឯកភាពចំពោះការបកស្រាយច្បាប់ដោយធ្វើការវិនិច្ឆ័យចំពោះការបកស្រាយសាលដីការចុងក្រោយដែលចេញដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ជាអាទ៍តាម ទស្សនៈវិស័យថាតើមានភាពផ្ទុយនឹងច្បាប់ដែរ ឬអត់ ហើយកែតម្រូវនូវសាលក្រម ឬសាលដីកាដែលមានភាពផ្ទុយពីច្បាប់ ឬបទដ្ឋានគតិយុត្តិ។

## ២. មូលហេតុនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ គឺធ្វើឡើងដោយមូលហេតុពីរយ៉ាងគឺ មូលហេតុទូទៅ និងមូលហេតុដាច់ខាត។ មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ដោយកំណត់ហេតុនីមួយៗ ដែលក្លាយជាហេតុនៃការធ្វើឧបាស្រ័យចំពោះសាលដីកាដើម ឬសាលក្រមដើម (ហេតុដែលធ្វើឲ្យបានត្រឹមត្រូវក្នុងការបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម)។ មានន័យថា នៅក្នុងករណីដែលមានមូលហេតុដូចនេះមែន តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបដិសេធនូវសាលដីកាដើម (សាលក្រមដើម)។ ផ្ទុយទៅវិញប្រសិនបើគ្មានមូលហេតុនេះទេ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវច្រានចោលនូវបណ្តឹងសាទុក្ខនោះ។ អត្ថិភាពនៃមូលហេតុដើមបណ្តឹងសាទុក្ខ ត្រូវច្រានចោលនូវបណ្តឹងសាទុក្ខនោះ។ អត្ថិភាពនៃមូលហេតុដើមបណ្តឹងសាទុក្ខ មិនមែនជាលក្ខខណ្ឌស្របច្បាប់ដើម្បីការដាក់ពាក្យបណ្តឹងសាទុក្ខទេ តែវា

ជាមូលហេតុនៃការបដិសេធចោលនូវសាលដីកាដើម (សាលក្រមដើម)។[37] តែចំពោះមូលហេតុដាច់ខាតវិញ គឺមានចែងច្បាស់នៅក្នុងក្រមនីតិរដ្ឋប្បវេណី។

❖ មូលហេតុដាច់ខាតនៃការធ្វើបណ្តឹងសាទុក្ខមានដូចជា[38]

១). ភាពផ្ទុយច្បាប់ក្នុងការចាត់តាំងតុលាការចេញសាលដីកា ឬសាលក្រម។

២). ការចូលរួមក្នុងការចេញសាលដីកា ឬសាលក្រមរបស់ចៅក្រម ដែលមិនបានត្រូវបានអនុញ្ញាតឲ្យចូលរួម។

៣). ភាពខុសសម្ថកិច្ចផ្តាច់មុខ។

៤). ការខ្វះសិទ្ធិតំណាង។

៥). ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការ បើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ។

៦). ការខ្វះការសំអាងហេតុ ឬភាពផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់នៃការចេញសាលដីកា ឬសាលក្រម។

### ៣. ការធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ អាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះដោយសាលាឧទ្ធរណ៍ សាលាដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិពិសេស និងចំពោះសាលក្រមចុងក្រោយដែល ត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ដោយរក្សាសិទ្ធិប្តឹងសាទុក្ខប៉ុណ្ណោះ។ បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងអំឡុងពេល ០១ ខែ គិតចាប់ពីថ្ងៃ ដែលទទួលបានការបញ្ជូននៃលិខិតសាលក្រម ឬសាលដីកាដើម ដូចអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ដែរ។

ដើម្បីប្តឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដើម (សាលាឧទ្ធរណ៍ ឬសាលាដំបូង) ក្នុងករណីនេះតុលាការដើម ត្រូវបានផ្ញើអោយបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ។[39] នៅក្នុងពាក្យបណ្តឹងសាទុក្ខ ក្រៅពីអត្តសញ្ញាណរបស់គូភាគី និងសញ្ញាណនៃសាលដីកានៃការជំនុំជម្រះលើកទី ២ សេចក្តីប្តឹងសាទុក្ខចំពោះសាលដីកាដើមបណ្តឹងសាទុកត្រូវសរសេរអំពីមូលហេតុនៃបណ្តឹងសាទុក្ខ។ ក្នុងករណី មូលហេតុនៃបណ្តឹងសាទុក្ខ មិនត្រូវសរសេរនៅក្នុងពាក្យបណ្តឹង ឬលិខិតនៃមូលហេតុនៃបណ្តឹងសាទុក្ខ មិនត្រូវបាន

[37] មាត្រា២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[38] មាត្រា២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[39] មាត្រា ២៨៧ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដាក់ក្នុងអំឡុងពេល ៣០ ថ្ងៃ ឬមានចំណុចខ្វះខាតនៃបណ្តឹងសាទុក្ខ តុលាការត្រូវបង្គាប់អោយកែតម្រូវក្នុងអំឡុងពេលសមរម្យ ហើយបើដើមបណ្តឹងសាទុក្ខ មិនកែតម្រូវក្នុងអំឡុងពេលសមរម្យ ឬបណ្តឹងសាទុក្ខនោះមិនស្របច្បាប់ មិនអាចកែតម្រូវបាន តុលាការត្រូវលើកចោលបណ្តឹងសាទុក្ខដោយដីកាសម្រេច។

## ៤. នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ និងការចេញសាលដីកា

ក្រោយពីតុលាការឧទ្ធរណ៍ចេញសាលដីកា រួចលើបណ្តឹងរបស់ភាគី បើភាគីនៅតែមិនយល់ស្របលើសេចក្តីសម្រេចនោះ ភាគីអាចធ្វើការប្តឹងមកតុលាការកំពូល ដែលជាតុលាការចុងក្រោយនៃការជំនុំជម្រះក្តី។ ហើយនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងសាទុក្ខ នឹងការចេញសាលដីកា នឹងធ្វើការបកស្រាយនូវចំណុចខាងក្រោម។

### ៤.១. ការជំនុំជម្រះបណ្តឹងសាទុក្ខ

តុលាការនៃបណ្តឹងសាទុក្ខត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលដីកាដើម ឬសាលក្រមដើមត្រឹមកម្រឹតនៃឧបាស្រ័យប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របច្បាប់។ ការជំនុំជម្រះលើអង្គសេចក្តី តុលាការត្រូវពិនិត្យមើលឯកសារដូចជាពាក្យបណ្តឹង លិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និងឯកសារផ្សេងៗទៀត ហើយបើយល់ឃើញថាគ្មានមូលហេតុនៃបណ្តឹងសាទុក្ខទេ តុលាការអាចចេញដីកាច្រានច្រោលពាក្យបណ្តឹងនេះដោយចេញសាលដីកា ដោយមិនឆ្លងកាត់ទាញការហេតុផលដោយផ្ទាល់មាត់។ ទោះបីជាបានទាញហេតុផលដោយផ្ទាល់មាត់ហើយ ក៏ដោយបើយល់ឃើញថា ពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ តុលាការត្រូវច្រានចោលពាក្យបណ្តឹងនោះ។ ក្នុងករណី ទទួលស្គាល់ថា បណ្តឹងសាទុក្ខមានមូលហេតុត្រឹមត្រូវ តុលាការត្រូវបដិសេធចោលសាលក្រម ឬសាលដីកាដើម មានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់លុបចោលនូវសាលក្រម ឬសាលដីកាដើម។ ក្រោយការបដិសេធ សាលក្រម ឬសាលដីកាដើមតុលាការពុំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្តីទេ ក្នុងករណីនេះ តុលាការត្រូវបញ្ជូនរឿងក្តីទៅកន្លែងដើមវិញ។ តុលាការដែលទទួលការបញ្ជូនត្រលប់ ត្រូវធ្វើការជំនុំជម្រះដោយទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីចំពោះរឿងក្តី តាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ ប៉ុន្តែការវិនិច្ឆ័យជាថ្មី របស់តុលាការដែលទទួលការបញ្ជូន ត្រូវទទួលអានុភាពចងនៃការវិនិច្ឆ័យលើអង្គហេតុនិងអង្គច្បាប់ ដែលតុលាការ នៃបណ្តឹងសាទុក្ខ យកជាមូលហេតុនៃការបដិសេធចោលសាលក្រមឬសាលដីកាដើម។ មានន័យថា តុលាការដើមមិនអាចវិនិច្ឆ័យដែលមានលទ្ធផលដូចសាលក្រម ឬ

សាលដីកាមុនដោយផ្អែកលើអង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធសាលក្រម ឬសាលដីកាដើមឡើយ។ ក្រៅពីការបដិសេធដោយការបញ្ជូនត្រលប់ទៅតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យដោយខ្លួនឯងជំនួសការបញ្ជូនត្រលប់បាន កាលបើមានមូលហេតុដូចមានចែងក្នុងមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ៤.១.១. ការលើកចោលនូវបណ្តឹងសាទុក្ខដោយដីកាសម្រេច

តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលបណ្តឹងសាទុក្ខ ដោយដីកាសម្រេច ប្រសិនបើបណ្តឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបានទេនោះ ឬប្រសិនបើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ មិនត្រូវបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ ឬប្រសិនបើមានភាពផ្ទុយគ្នានឹងមាត្រា ២៨៩ កថាខណ្ឌទី ២ និង៣ (មាត្រា ២៩០)។ ក្នុងករណីដែលមិនបានចេញដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខទេ ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ទៅចុងបណ្តឹងសាទុក្ខ ហើយត្រូវផ្តល់ឱកាសអោយចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀម។[40] តុលាការនៃបណ្តឹងសាទុក្ខ ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលដីកាដើម ឬសាលក្រមដើមត្រឹមតែកម្រិតនៃឧបាស្រ័យប៉ុណ្ណោះដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របនឹងច្បាប់។[41]

### ៤.១.២. សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

ក្នុងការជំនុំជម្រះលើអង្គសេចក្តីតុលាការត្រូវមើលជាបឋមទៅលើឯកសារជា លាយលក្ខ័អក្សរដែលមានដូចជា លិខិតពាក្យបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និងឯកសារផ្សេងៗទៀត ហើយប្រសិនបើតុលាការរកឃើញដោយផ្អែកលើឯកសារទាំងអស់នោះថា គ្មានមូលហេតុប្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខអាចចេញសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខនោះ ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន។[42] ទោះក្នុងករណីដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយក៏ដោយ ប្រសិនបើពិនិត្យទៅឃើញថាពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ តុលាការនៃ បណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ។[43]

---

[40] មាត្រា២៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[41] មាត្រា២៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[42] មាត្រា២៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[43] មាត្រា២៨៦ និងមាត្រា២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៥. សាលដីកាទទួលស្គាល់នូវបណ្ដឹងសាទុក្ខ

ក្នុងករណីទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើបណ្ដឹងសាទុក្ខ តុលាការត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីកាដើម។[44] ការបដិសេធចោលមានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលដីកាដើម ឬសាលក្រមដើម។ តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលបដិសេធចោលនូវសាលដីកាដើម ឬសាលក្រមដើម (ការបកស្រាយបញ្ច្រាស់នៃមាត្រា ២៩៨)។

### ៥.១. ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើម ឬការបដិសេធចោល និងផ្ទេររឿងក្ដី

ជាគោលការណ៍ ក្រោយការបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមតុលាការពុំចាំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្ដីទេ ដូច្នេះហើយករណីនេះ ខុសពីករណីនៃការលុបចោលនូវសាលក្រម ដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនរឿងក្ដីទៅតុលាការដើមវិញ។ ជាបឋមក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសាជាថ្មីមិនអាចធ្វើការជំនុំជម្រះ ជំនួសសាលក្រម ឬសាលដីកាដើមទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនរឿងក្ដីនោះទៅតុលាការដើមវិញ ឬក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រលប់នោះមិនសមស្របទេ ដោយសារមានការកម្រិតនៃកថាខណ្ឌទី ៣ មាត្រា ២៩៩ (ដែលមានការពន្យល់ខាងក្រោម) ត្រូវផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។ [45] តុលាការដែលបានទទួលនូវការបញ្ជូនត្រលប់មកវិញ ឬដែលបានទទួលនូវការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី ចំពោះរឿងក្ដីនោះតាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ។[46] ការទាញហេតុផលដោយផ្ទាល់មាត់នោះ ជាសារធាតុ គឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក។ ប៉ុន្តែដូចដែលនឹងពន្យល់ខាងក្រោម ចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នោះភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។ ក្នុងករណីនេះសេចក្ដីវិនិច្ឆ័យលើអង្គច្បាប់ និងអង្គហេតុ ដែលតុលាការនៃបណ្ដឹងសាទុក្ខបានយកជាមូលហេតុនៃការបដិសេធចោលដែលមាន ចំណងទៅលើតុលាការដែល

---

[44] មាត្រា២៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[45] មាត្រា២៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[46] មាត្រា២៩៩ កថាខណ្ឌទី២ វាក្យខ័ណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បានទទួលការបញ្ជូន ឬការផ្ទេរ។[47] នេះគឺដោយសារតែ ប្រសិនបើតុលាការដើមនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬនៅតែធ្វើការចាត់ចែងដូចមុនដដែលនោះ ទោះជាតុលាការនៃបណ្តឹងសាទុក្ខបានបញ្ជូនត្រឡប់ទៅវិញប៉ុន្មានដងក៏ដោយ ក៏រឿងក្តីនោះមិនអាចដោះស្រាយចប់ឡើយ។ សេចក្តីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិតតែសេចក្តី វិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបាន ដូចជាអង្គហេតុដែលទាក់ទងទៅនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ។ [48] អានុភាពចង នៃសេចក្តីវិនិច្ឆ័យលើអង្គច្បាប់ដែលសេចក្តីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះដែលមាននៅក្នុងសាលដីការដើម ឬសាលក្រមដើម បានក្លាយទៅជាមូលហេតុនៃការបដិសេធចោល។ ហេតុដូច្នេះ អានុភាពនេះតម្រូវអោយតុលាការដែលទទួលការបញ្ជូន ឬការផ្ទេរជៀសវាងធ្វើការសេចក្តីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះប៉ុណ្ណោះ តែមិនហាមឃាត់អោយតុលាការនោះចេញសាលដីការ ឬសាលក្រមដែលមានសេចក្តីសន្និដ្ឋានដូចគ្នានឹងសាលដីកា ឬសាលក្រមមុនដោយយកការបកស្រាយផ្សេងនូវអង្គច្បាប់ដែលអាចធ្វើបាន។

ដើម្បីធានានូវអានុភាពចងក្នុងការវិនិច្ឆ័យនោះបានគឺចៅក្រមណា ដែលមានការពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើមដែលត្រូវបានបដិសេធចោល មិនត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការសម្រេចសេចក្តីក្រោយនោះបានទេ។ [49] ដើម្បីកុំអោយមានឧបសគ្គជាក់ស្តែងដោយសារការកម្រិតនេះច្បាប់អនុញ្ញាតអោយផ្ទេររឿងក្តីជំនួសការបញ្ជូនត្រឡប់ទៅវិញ។

## ៥.២. ការបដិសេធ និងការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខដែលបានបដិសេធចោលនូវសាលដីកាដើម ឬ (សាលក្រមដើមក្នុងករណីដែលមានការព្រមព្រៀងផ្លោះទៅ បណ្តឹងសាទុក្ខជាតទៅពន្យល់តែករណីដែលមានបណ្តឹងសាទុក្ខចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ) តុលាការអាចធ្វើការវិនិច្ឆ័យ ដោយខ្លួនឯងជំនួសសាលដីកាដើមនោះបានក្នុងករណីដែលអាចចេញនូវ សាលដីកាជំនួសសាលដីកានោះបានដោយផ្អែកលើ អង្គហេតុដែលត្រូវបានកំណត់ជាស្ថាពរនៅក្នុង សាលដីកាដើមតែប៉ុណ្ណោះ។[50] នៅក្នុងសាលដីកាដែលបានជំនួសសាលដីកាដើម គឺជាចម្លើយចំពោះពាក្យបណ្តឹងឧទ្ធរណ៍។ ហេតុដូច្នេះ មានករណីខ្លះដែលមិនឆ្លើយផ្ទាល់ចំពោះបណ្តឹងនៃការជំនុំជម្រះលើកទី ១

[47] មាត្រា១៨៥ កថាខណ្ឌទី២ និងអនុវត្តផងដែរនូវមាត្រា២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[48] មាត្រា២៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[49] មាត្រា២៩៩ កថាខណ្ឌទី២ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[50] មាត្រា៣០០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដែរ។ ករណីដែលតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យដោយខ្លួនឯង និងចេញសាលដីកាជំនួសសាលដីកាដើមមានករណីដូចតទៅ:

ជាដំបូង មានករណីដែលតុលាការនៃបណ្តឹងសាទុក្ខ ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និងលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ឬផ្ទេររឿងក្តីទៅតុលាការនៃការជំនុំជម្រះលើកទី ១។ ក្នុងចំណោមករណីនេះមានពីរករណី គឺ **១** ករណីដែលសាលដីកាដើមដែលត្រូវបានបដិសេធចោល រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលច្រានចោលការទាមទារ ឬ រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ និង **២** ករណីដែលគួរតែអោយវិនិច្ឆ័យឡើងវិញពីការជំនុំជម្រះលើកទី ១ ដោយសារការជំនុំជម្រះលើកទី ១ ពីមុននោះមិនគ្រប់គ្រាន់។

ក្រៅពីករណីខាងលើ មានករណីដែលតុលាការនៃបណ្តឹងសាទុក្ខលើកចោល ឬច្រានចោលបណ្តឹងឧទ្ធរណ៍ ឬក្នុងករណីដែលទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និងចេញសាលដីកាផ្ទាល់ចំពោះបណ្តឹង (លើកចោលបណ្តឹង ច្រានចោលការទាមទារ ឬទទួលស្គាល់ការទាមទារ)។ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខ បានបដិសេធចោលសាលដីកាដើម ដោយហេតុថា សាលដីកាដើមនោះមានកំហុសក្នុងការអនុវត្ត ឬបកស្រាយច្បាប់ ឬបទដ្ឋានគតិយុត្តិផ្សេងទៀត ចំពោះអង្គហេតុដែលត្រូវបានកំណត់ជាស្ថាពរ ហើយប្រសិនបើអាចសម្រេចសេចក្តីអំពីអង្គហេតុ ចំពោះរឿងក្តីនោះបានដោយតែកែតម្រូវការអនុវត្ត ឬបកស្រាយច្បាប់ ឬបទដ្ឋានគតិយុត្តិនោះអោយបានត្រឹមត្រូវប៉ុណ្ណោះ ១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ តុលាការនៃ បណ្តឹងសាទុក្ខ នឹងច្រានចោលបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ហើយសម្រេចដោយខ្លួនឯង ទទួលស្គាល់ ឬច្រានចោលការទាមទារ។[51] ម៉្យាងទៀត ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលសាលដីកាដើម ដោយហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ (មាត្រា ៣០០ កថាខណ្ឌទី ២) ប្រសិនបើសាលក្រមនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍ ហើយប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ បានចេញសាលក្រមសម្រេចអង្គសេចក្តីវិញ តុលាការនៃបណ្តឹងសាទុក្ខត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះនឹងត្រូវលើកចោលបណ្តឹងដោយខ្លួនឯង។[52]

[51] មាត្រា៣០០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[52] មាត្រា៣០០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ផ្នែកទី ៣៖ បណ្ដឹងជំទាស់

### ១. អត្ថន័យនៃបណ្ដឹងជំទាស់

បណ្ដឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេបដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្ដីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកា។ នីតិវិធីបណ្ដឹងជំទាស់មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្ដឹងឧទ្ធរណ៍ ឬសាទុក្ខហើយត្រូវបញ្ចប់ដោយដីកាសម្រេច (នីតិវិធីចេញដីកាសសម្រេច)។ បណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ ហេតុដូច្នេះ ត្រង់ចំនុចនោះខុសពីការតវ៉ាដែលជាឧបាស្រ័យចំពោះដីកាសម្រេចទៅតុលាការសាមី។ ចំពោះដីកាសម្រេចដែលជាសេចក្ដីសម្រេចមិនមែនជាសាលក្រម ឬសាលដីកា ហើយតុលាការដែលជំនុំជម្រះលើបណ្ដឹងជំទាស់ហៅថា **តុលាការនៃបណ្ដឹងជំទាស់** (សាលាឧទ្ធរណ៍ ឬតុលាការកំពូល)។ ដីការសម្រេចដែលអាចប្ដឹងជំទាស់បាន លុះត្រាតែមានបញ្ញាត្តិក្នុងច្បាប់ ដូចជា ដីកាសម្រេចលើកចោល បណ្ដឹងក្នុងករណីភាគីមិនកែតម្រូវជាអាទិ៍ ប៉ុន្តែដីកាសម្រេចដែលលើកបណ្ដឹងជំទាស់មិនអាចប្ដឹងជំទាស់ទៀតបានឡើយ។

### ២. មូលហេតុនៃបណ្ដឹងជំទាស់

មូលហេតុនៃបណ្ដឹងជំទាស់ គឺដោយសាតែភាគីមិនពេញចិត្តនឹងសេចក្ដីសម្រេចដែលជាប្រភេទនៃដីកាសម្រេចដែលសាលាដំបូងចេញមក ឬនៅពេលដែលបុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តិរបស់ខ្លួនដោយសារដីកាសម្រេច។

### ៣. ដំណើរការនៃបណ្ដឹងជំទាស់

ដើម្បីប្ដឹងជំទាស់បានភាគីត្រូវដាក់ពាក្យបណ្ដឹងជាមុនសិនដែលត្រូវឆ្លងកាត់នូវដំណើរការនៃបណ្ដឹងជំទាស់ដូចជា ការធ្វើបណ្ដឹងជំទាស់ និងនីតិវិធីនៃការជម្រះក្ដីលើបណ្ដឹងជំទាស់ដែលត្រូវរៀបរាប់ដូចខាងក្រោម៖

#### ៣.១. ការធ្វើបណ្ដឹងជំទាស់

ផលប្រយោជន៍ក្នុងការប្ដឹងជំទាស់ ត្រូវបានទទួលស្គាល់ចំពោះភាគី ឬតតិយជនដែលបានបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចដើម។ បណ្ដឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ០១

សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីការសម្រេច។[53] អំឡុងពេលនេះមិនអាចពន្យារបានទេ។ ដើម្បីធ្វើបណ្តឹងជំទាស់ គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្តូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះក៏បណ្តឹងជំទាស់នោះមិនបែរជាគ្មានសុពលភាពដែរ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់មិនមានសរសេរអំពីមូលហេតុនោះទេ នោះដើមបណ្តឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងជំទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ក្នុងអំឡុងពេល ០២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។[54] នៅពេលទទួលបានពាក្យបណ្តឹងជំទាស់ តុលាការដើមត្រូវផ្ញើពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ឱ្យបានឆាប់រហ័ស។ ពេលដែលបានទទួលការផ្ញើពាក្យបណ្តឹងជំទាស់ហើយតុលាការនៃបណ្តឹងជំទាស់ត្រូវពិនិត្យពាក្យបណ្តឹងជំទាស់នោះហើយប្រសិនបើមានចំណុចណាដែរមិនស្របនឹងទម្រង់ ត្រូវបង្គាប់ឱ្យដើមបណ្តឹងជំទាស់ធ្វើការកែតម្រូវ។ ប្រសិនបើភាគីនោះមិនធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេ នោះតុលាការនឹងត្រូវលើកចោលពាក្យបណ្តឹងជំទាស់នោះដោយដីកាសម្រេច ។[55]

ចំពោះដីការម្រេចដែលជាសេចក្តីសម្រេចមិនមែនសាលក្រម ឬសាលដីកាហើយតុលាការដែលជំនុំជម្រះលើបណ្តឹងជំទាស់ ហៅថា **តុលាការនៃបណ្តឹងជំទាស់** (សាលាឧទ្ធរណ៍ ឬតុលាការកំពូល)។ ដីកាសម្រេចដែលអាចប្តឹងជំទាស់បានលុះត្រាតែមានបញ្ញាត្តិក្នុងច្បាប់ ដូចជាដីកាសម្រេចលើកចោល បណ្តឹងក្នុងករណីភាគីមិនកែតម្រូវជាអាទិ៍ ប៉ុន្តែដីកាសម្រេចដែលលើកបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ។

ការដាក់ពាក្យបណ្តឹង និងការជំនុំជម្រះលើបណ្តឹងជំទាស់ ត្រូវអនុលោមទៅតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចដែលត្រូវបានធ្វើឡើងដោយសាលាដំបូងដូចនេះបញ្ញាត្តិនៃមាត្រា ២៦៣, ២៦៥ កថាខណ្ឌទី ២, ២៦៨, ២៧០ និង ២៧៣ ត្រូវបានយកមកអនុវត្តផងដែរក្នុងករណីនៃនីតិវិធីតុលាការនៃបណ្តឹងជំទាស់។ លើកលែងតែករណីមានបញ្ញាត្តិផ្ទុយនឹងលក្ខណៈនៃបណ្តឹងជំទាស់ដូចជា អំឡុងពេលប្តឹងជំទាស់ ការទាញហេតុ

[53] មាត្រា៣០០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[54] មាត្រា៣០០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[55] មាត្រា៣០៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផលដោយឆន្ទានុសិទ្ធិជាអាទិ៍។ ក្រៅពីនេះបញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និងនីតិវិធីទាក់ទងការជំនុំជម្រះលើ បណ្ដឹងសាទុក្ខត្រូវយកមកអនុវត្តចំពោះការជំនុំជម្រះលើបណ្ដឹងជំទាស់ក្នុងករណីបណ្ដឹងជំទាស់ចំពោះដីកាសម្រេចដែលត្រូវធ្វើឡើងដោយសាលាឧទ្ធរណ៍ ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ លើកលែងតែបញ្ញត្តិដែលមានភាពផ្ទុយនឹងលក្ខណៈបណ្ដឹងជំទាស់។ ដូចនេះ បណ្ដឹងជំទាស់ត្រូវដាក់ទៅតុលាការកំពូលតាមមាត្រា ២៨៣ កថាខណ្ឌទី១ ហើយបណ្ដឹងជំទាស់នោះអាចធ្វើទៅបានលុះត្រាតែ មានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលជះឥទ្ធិពលលើដីកាសម្រេចដើមប៉ុណ្ណោះ។

### ៣.២. អំឡុងពេលសម្រាប់ប្ដឹងជំទាស់

១. បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ សប្ដាហ៍ ដែលគិតចាប់ពីថ្ងៃដែលបានទទួលអំពីដីកាសម្រេច។

២. អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះមិនអាចពន្យាពេលបានឡើយ។[56] ប៉ុន្តែក្នុងករណីច្បាប់កំណត់ជាក់លាក់ បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងរយៈពេល ០២ សប្ដាហ៍ ដូចជាបណ្ដឹងជំទាស់ចំពោះការលើកចោលសេចក្ដីសម្រេច ដូចមានចែងក្នុងមាត្រា ៥៨៥។

## ៤. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្ដឹងជំទាស់

### ៤.១. ភាគីនៃបណ្ដឹងជំទាស់

ចំពោះនីតិវិធីបណ្ដឹងជំទាស់ មិនមែនធ្វើតាមវិធីតទល់គ្នារវាងភាគីនៅគ្រប់ពេលវេលា។ ប៉ុន្តែនៅក្នុងករណីដែលចំណុចដែលត្រូវបានវិនិច្ឆ័យដោយដីកាសម្រេចដែលជា កម្មវត្ថុនៃបណ្ដឹងជំទាស់មានមូលដ្ឋានដែលមានបុគ្គលនោះបានចូលរួមនៅក្នុងនីតិវិធីទាំងឡាយ នៃការប្ដឹងជំទាស់នោះ។ ឧទាហរណ៍ក្នុងករណីដែលដើមបណ្ដឹងបានដាក់ពាក្យសុំឱ្យតុលាការចេញ ដីកាសម្រេចបង្គាប់ឱ្យចុងចម្លើយផ្ដល់ឯកសារដែលចុងចម្លើយកាន់កាប់ ហើយតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារដោយទទួលស្គាល់ពាក្យសុំនោះប្រសិនបើចុងចម្លើយប្ដឹងជំទាស់ចំពោះ ដីកាសម្រេចនោះ ចុងចម្លើយត្រូវយកដើមចោទមកធ្វើជាភាគីម្ខាងទៀត។ រីឯប្រសិនបើចុងចម្លើយប្ដឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលពាក្យសុំដើមចោទនោះត្រូវយក ចុងចម្លើយមកធ្វើជាភាគីម្ខាងទៀតវិញ។ ក៏ប៉ុន្តែមានករណីខ្លះដែលសេចក្ដីសម្រេចធ្វើឡើងតាមរយៈដីកាសម្រេច តែគ្មានបុគ្គលណាពាក់ព័ន្ធ

[56] មាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

នឹងផលប្រយោជន៍ទេដីកាសម្រេចដាក់ពិន័យស៊ីវិល ចំពោះតតិយជនដែលមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារនៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យ និង ខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយ ត្រូវអនុលោមទៅតាមករណីនៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់។

### ៤.២. បណ្តឹងជំទាស់ និងការបង្ខាក់នូវអានុភាពនៃដីកាសម្រេចដើម

ដីកាសម្រេចមានភាពខុសគ្នាពីសាលក្រម ឬសាលដីកា គឺជាគោលការណ៍ ដីកាសម្រេចនឹងបង្កើតនូវអានុភាពចាំបាច់ ដើម្បីសម្រេចនូវខ្លឹមសារនៃការសម្រេចសេចក្តីដូចជាអានុភាពអនុវត្ត និងអានុភាពបង្កើតទំនាក់ទំនងគតិយុត្តិ ជាដើមដោយការជូនដំណឹងដែលគេអាចទទួលស្គាល់បានថាសមរម្យមួយតែប៉ុណ្ណោះក៏ប៉ុន្តែពេលដែល មានបណ្តឹងជំទាស់អានុភាពនៃដីកាសម្រេចដើមដែលបានកើតឡើងម្តងរួចហើយត្រូវបានបង្អាក់។ ឧទាហរណ៍ ប្រសិនបើបណ្តឹងជំទាស់ត្រូវបានដាក់ចំពោះដីកាសម្រេចបង្គាប់អោយផ្តល់ឯកសារភាគី ឬតតិយជនដែលត្រូវបានបង្គាប់នោះ មិនចាំបាច់ផ្តល់ឯកសារដែលតុលាការបង្គាប់អោយផ្តល់ឡើយ។ ជាទូទៅដីកាសម្រេចអាចប្តឹងជំទាស់ប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី និងមានភាពចំបាច់ក្នុងការចូលជាស្ថាពរអោយបានឆាប់រហ័ស។ ហេតុដូច្នេះ អានុភាពនៃដីកាសម្រេចដើមត្រូវផ្អាកដោយមានការដាក់បណ្តឹងជំទាស់តែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានចាប់ផ្តើមដោយយកដីកាសម្រេចនោះមកធ្វើជាលិខិតអនុវត្ត[57] ដើម្បីផ្អាកការអនុវត្តដែលកំពុងធ្វើឡើងដោយស្ថាប័នអនុវត្តចាំបាច់ត្រូវដាក់ឯកសារដូចមានរៀបរាប់នៅក្នុងចំណុចទាំងឡាយនៃមាត្រា ៣៧០ កថាខណ្ឌទី ១ និងទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ ប្រសិនបើបណ្តឹងជំទាស់ត្រូវបានធ្វើឡើងតុលាការនៃបណ្តឹងជំទាស់ ឬតុលាការដើម អាចបង្គាប់អោយផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬបង្គាប់អោយធ្វើការចាត់ចែងចាំបាច់ផ្សេងទៀតរហូតដល់ពេលដែល មានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ។[58]ប៉ុន្តែការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬការចាត់ចែងផ្សេងទៀតនោះ អាចធ្វើបានតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ។

[57] មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[58] មាត្រា៣០៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៤.៣. នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់

ដោយហេតុថា នីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានថា តើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើការទាញហេតុផលផ្ទាល់មាត់។ នៅក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនៃបណ្តឹងជំទាស់ អាចសួរម្ចាស់បណ្តឹងជំទាស់ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងផលប្រយោជន៍ដែលទាក់ទងនឹងបណ្តឹងជំទាស់នោះបាន។ [59] ក្នុងការជំនុំជម្រះបណ្តឹងជំទាស់ភាគីអាចដាក់អង្គហេតុថ្មី និងភស្តុតាងថ្មីដូចជាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ សេចក្តីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ គឺជាដីកាសម្រេចដែលយកខ្លឹមសារនៃដីកាសម្រេចនោះត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ប៉ុន្តែចំពោះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យ និងខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយដែលត្រូវអនុលោមទៅតាមករណី នៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់។[60]

## ៥. ប្រភេទដីកាសម្រេចដែលអាចប្តឹងជំទាស់បាន

ជាទូទៅ ដីកាសម្រេចទាំងឡាយដែលធ្វើឡើងដោយតុលាការអំពីចំណុចដែលបានក្លាយទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីរហូតដល់ចេញសាលក្រម ឬសាលដីកាចុងក្រោយត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយនឹងសាលក្រម ឬសាលដីកាចុងក្រោយដោយបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ។ ក៏ប៉ុន្តែ ប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនៃនីតិវិធី ឬដែលកើតឡើងដោយនីតិវិធីនៃការជំនុំជម្រះសុទ្ធតែដាក់ឱ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះ ការណ៍នេះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឱ្យមានការយឺតយ៉ាវក្នុងការជំនុំជម្រះរឿងក្តីនោះដោយសារតែបញ្ហាដែលកើតចេញពីនោះ។ ដូច្នេះ ជាការល្អប្រសិនបើឱ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្តីនៃរឿងក្តីហើយដែលត្រូវការសម្រេចឱ្យឆាប់ អាចដោះស្រាយបានដោយនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ។ ម៉្យាងវិញទៀតក្នុងករណីដែលការបញ្ចប់នីតិវិធីសង្ខេបដោយដីកាសម្រេច ឬក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជន

[59] មាត្រា៣០៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[60] មាត្រា៣០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្រៅពីភាគី វាចាំបាច់ដែលត្រូវបើកផ្លូវឱ្យតតិយជនជាដើមនោះដែលមានបំណងចង់ធ្វើបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចនោះអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន។ ដូច្នេះហើយក្នុងករណីដែលទទួលស្គាល់ថា មានការចាំបាច់ក្រមនីតិវិធីរដ្ឋប្បវេណីនេះមានចែងថាអាចប្តឹងជំទាស់ចំពោះដីកាសម្រេចបាន។

បណ្តឹងជំទាស់អាចធ្វើឡើងបានលុះត្រាតែមានបញ្ញត្តិច្បាប់។ [61] ជាទូទៅដីកាសម្រេចទាំងឡាយណាដែលធ្វើឡើងដោយតុលាការអំពីចំណុចដែលបានក្លាយ ទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីហូតចេញសាលក្រម ឬសាលដីកាចុងក្រោយត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយដោយដើមបណ្តឹងឧទ្ធរណ៍ ឬដើមបណ្តឹងសាទុក្ខ។ [62] ប៉ុន្តែប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនីតិវិធី ឬដែលកើតឡើងដោយនីតិវិធីជំនុំជម្រះសុទ្ធតែដាក់ពាក្យឲ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះ ករណីនេះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឲ្យមានការយឺតយូរក្នុងការជំនុំជម្រះរឿងក្តីនោះដោយសារតែបញ្ហាដែលកើតឡើងនោះ។ ដូច្នេះជាការល្អប្រសើរបើឲ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្តីនៃរឿងក្តី ហើយដែលត្រូវសម្រេចឲ្យឆាប់អាចដោះស្រាយបាន ដោយនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ។ ម្យ៉ាងវិញទៀតក្នុងករណីដែលបញ្ចប់នីតិវិធីដោយដីកាសម្រេច ឬក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជនក្រៅភាគី វាជាការចាំបាច់ដែលត្រូវបើកផ្លូវឲ្យតតិយជនជាដើមនោះដែលចង់ធ្វើឧបាស្រ័យចំពោះដីកាសម្រេចនោះ មានការចាំបាច់ ក្រមនីតិវិធីរដ្ឋប្បវេណីនេះមានចែងថាអាចប្តឹងជំទាស់ចំពោះដីកានោះបាន។

- ✓ ដីកាសម្រេចដែលអាចប្តឹងជំទាស់បានមានដូចខាងក្រោយ៖
  - ដីកាសម្រេចផ្ទេរ និងដីកាសម្រេចលើពាក្យបណ្តឹង (មាត្រា២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចដែលសម្រេចថា ដកហូត ឬបណ្តឹងជិតចិត្តមិនត្រឹមត្រូវ (មាត្រា៣០ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
  - ដីកាសម្រេចនូវការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យចូលអន្តរាគមន៍ (មាត្រា៥៥ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[61] មាត្រា២៥៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[62] មាត្រា២៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- ដីកាសម្រេចពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ នូវការសងប្រាក់នៃប្រាក់ប្រដាប់ក្ដី (មាត្រា ៦៤ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចអំពីពាក្យសុំ ឲ្យតុលាការបង្គាប់ឲ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី ដោយដើមចោទគ្មានទីលំនៅច្បាស់លាស់ ឬពិតប្រាកដ (មាត្រា៦៧ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យជួយសង្គ្រោះលើពាក្យបណ្ដឹង (មាត្រា៧០ នៃកថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យលុបចោលដីកាសម្រេចឲ្យជួយសង្គ្រោះលើពាក្យបណ្ដឹង (មាត្រា៧០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យលុបចោលប្រាតិភោគ (មាត្រា៧៣ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកបណ្ដឹងចោល (មាត្រា៧៨ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឲ្យនាំខ្លួនសាក្សី និងដីកាសម្រេចពិន័យសាក្សីជាសាច់ប្រាក់ ដោយមិនព្រមចូលតាមដីកាកោះ (មាត្រា១៣២ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចពិន័យភាគីដែលបន្លំសេចក្ដីថ្លែងការណ៍ (មាត្រា១៤០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចដែលសម្រេចថា បណ្ដឹងផាត់ចោល (មាត្រា១៤៥ កថាខណ្ឌ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឲ្យផ្ដល់ឯកសារ (មាត្រា១៥២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យតតិយជនបង់ប្រាក់ពិន័យដោយមិនគោរពដីកា សម្រេចបង្គាប់ឲ្យផ្ដល់ឯកសារ (មាត្រា១៥៤ កថាខណ្ឌ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកចោលពាក្យសុំឲ្យរក្សាការពារភស្តុតាង (មាត្រា១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្ដឹង (មាត្រា១៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- ដីកាសម្រេចកែតម្រូវសាលក្រម (មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកចោល និងច្រានចោលបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី (មាត្រា៣១៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី (មាត្រា៣១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន (មាត្រា៣២៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៥៥ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឲ្យអាជ្ញាសាលាលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៥៥ កថាខណ្ឌទី២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ (មាត្រា៣៥៥ កថាខណ្ឌ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចការលុបចោលការរឹបអូស និងដីកាសម្រេចអនុញ្ញាតឲ្យរឹបអូស (មាត្រា៣៨១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឲ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស (មាត្រា៣៩០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា៤១៩ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុល (មាត្រា៤១៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ (មាត្រា៤៧៥ នៃក្រមនីតិវីធីរដ្ឋប្បវេណី)។
- ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ (មាត្រា៤៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- ដីកាសម្រេចឲ្យប្រគល់នាវា (មាត្រា៤៨៣ កថាខណ្ឌ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- ដីកាសម្រេចឲ្យយកវត្ថុបញ្ចាំមកសងផ្ទាល់ (មាត្រា៥០៤ កថាខណ្ឌទី៦ នៃក្រម នីតិវិធីរដ្ឋប្បវេណី)។

## ៦. វិសាលភាពនៃបណ្តឹងជំទាស់

ក្នុងកថាខណ្ឌនេះយើងនឹងធ្វើការសិក្សាអំពីចំណុច នៃការប្តឹងជំទាស់អំពីដីកាសម្រេចនៃសាលាឧទ្ធរណ៍ និងការប្តឹងជំទាស់ចំពោះដីកាសម្រេចចំពោះចៅក្រមទទួលបញ្ហា ឬការប្រគល់សិទ្ធិ។

### ៦.១. ការប្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍

បើទោះជាការប្តឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់[63] ក៏ដោយ ក៏ប៉ុន្តែចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ដែល តុលាការនៃបណ្តឹងជំទាស់នោះចេញមិនអាចប្តឹងជំទាស់ទៀតបានឡើយ។[64] ឧទាហរណ៍ ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ភាគីមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចចុងក្រោយអំពីបណ្តឹងជំទាស់ដែលត្រូវបានធ្វើបានធ្វើដោយសាលាឧទ្ធរណ៍ដែលជាតុលាការនៃបណ្តឹងជំទាស់នោះទៅ តុលាការកំពូលថែមទៀតបានឡើយ។ ការអនុវត្តបែបនេះគឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល ។

ផ្ទុយទៅវិញចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បាន ធ្វើឡើងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្តឹងជំទាស់ទៅតុលាការកំពូលបានប្រសិនបើមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្តឹងជំទាស់នេះ គឺជាបណ្តឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹង ការអនុវត្តចំពោះបណ្តឹងសាទុក្ខចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១[65] ដោយហេតុនោះ បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់ទាំងនោះលើកលែងតែករណីដែលបញ្ញត្តិជំនុំជម្រះលើកទី ១ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់ទាំងនោះលើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬនីតិវិធីនោះ។ ហេតុដូច្នេះនៅក្នុងករណីនេះបណ្តឹងជំទាស់នេះអាចធ្វើទៅបានដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។

---

[63] មាត្រា២៥៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[64] មាត្រា២៥៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[65] មាត្រា៣០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ម្យ៉ាងវិញទៀត មានខ្លះករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចក្នុងនាមជាតុលាការនៃការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍។ ក្នុងករណីនេះភាពអាច ឬមិនអាចប្ដឹងជំទាស់ជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍ចេញក្នុងនាមជា តុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍អាស្រ័យទៅលើការអនុវត្តបញ្ញត្តិនៃមាត្រា ២៥៩ (ប្រភេទនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ហេតុដូច្នេះហើយ លើកលែងតែករណីដែលមានបញ្ញាត្តិច្បាប់ដែលអនុញ្ញាតឱ្យប្ដឹងជំទាស់ ភាគីមិនអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍បានឡើយ។ ក្នុងករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចដំបូងក្នុងនាមជា តុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍។ ប្រសិនបើបណ្ដឹងជំទាស់ចំពោះដីកាសម្រេចត្រូវបានធ្វើឡើងផ្អែកលើបញ្ញាត្តិនៃគន្ថីទី១ (បទបញ្ញត្តិទូទៅ) ដែលអាចអនុវត្តផ្ទាល់ចំពោះបណ្ដឹងឧទ្ធរណ៍ ភាគីអាចប្ដឹងជំទាស់។ ឧទាហរណ៍ចំពោះដីកាសម្រេចដែលសម្រេចថាការដកហូត ឬបណ្ដឹងជិតចិត្តចៅក្រមនៃសាលាឧទ្ធរណ៍ មិនត្រឹមត្រូវអាចប្ដឹងជំទាស់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ មាត្រា ៣០ នៅក្នុងគន្ថីទី ១។ ផ្ទុយទៅវិញចំពោះដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការ នៃការជំនុំជម្រះ បណ្ដឹងឧទ្ធរណ៍ មិនអាចប្ដឹងជំទាស់បានឡើយដោយសារបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១៥២ មិនត្រូវអនុវត្តដោយផ្ទាល់ចំពោះបណ្ដឹងឧទ្ធរណ៍បានទេ គឺត្រូវអនុវត្តដូចគ្នាផងដែរក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹងគន្ថីទី ២ នៃនីតិវិធីនៃការជំនុំជម្រះលើកទី ១ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២៧២។

### ៦.២. បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ការប្រគល់សិទ្ធិ

ក្នុងករណីដែលភាគីមិនសុខចិត្តទៅនឹងដីកាសម្រេចដែលធ្វើឡើងដោយ ចៅក្រមដែលបានទទួលការបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិ ជាបឋមវាជាការសមរម្យដែលត្រូវដាក់ដីកាសម្រេចរបស់តុលាការ។ ដូច្នេះបើភាគីដែលមិនយល់ស្របចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចប្ដឹងតវ៉ាទៅតុលាការដែលទទួលបណ្ដឹងដែលក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្ដឹងជំទាស់បានប្រសិនបើដីការសម្រេចនោះ ជាដីកាសម្រេចរបស់តុលាការដែលទទួលបណ្ដឹង ហើយចំពោះដីកាសម្រេចអំពីការតវ៉ានោះតែប៉ុណ្ណោះអាចប្ដឹងជំទាស់បាន។ ក៏ប៉ុន្តែក្នុងករណីដែលតុលាការដែលទទួលបណ្ដឹង ជាតុលាកំពូល ឬសាលាឧទ្ធរណ៍ភាគីអាចប្ដឹងតវ៉ាបានលុះត្រាតែច្បាប់បានអនុញ្ញាតឱ្យប្ដឹងជំទាស់ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង។ ប៉ុន្តែក្នុងករណីនេះ ប្រសិនបើតុលាការដែលទទួលបណ្ដឹងជាតុលាការ

កំពូលចំពោះដីកាសម្រេចអំពីការតវ៉ានោះមិនអាចប្ដឹងជំទាស់បានដោយសារគ្មានតុលាការជាន់ខ្ពស់ជាងតុលាការកំពូល។ ចំពោះការតវ៉ាដែលបានកំណត់នៅក្នុងមាត្រា ៣០២ នេះប្រសិនបើដីកាសម្រេចដែលជាកម្មវត្ថុនៃការតវ៉ានោះត្រូវបានធ្វើឡើងដោយតុលាការដែលទទួល បណ្ដឹងវិញ ត្រូវក្លាយទៅជាកម្មវត្ថុនៃបណ្ដឹងជំទាស់វិញ។ ហេតុដូច្នេះ ការតវ៉ានោះត្រូវធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ៣០៣ ចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច។ អំឡុងពេលនេះមិនអាចពន្យាពេលបាន។ ដើម្បីធ្វើបណ្ដឹងជំទាស់បាន ត្រូវដាក់ពាក្យបណ្ដឹងជំទាស់ទៅតុលាការជាដើម។ នៅក្នុងពាក្យបណ្ដឹងជំទាស់គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្ដូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះក៏បណ្ដឹងជំទាស់នោះមិនប្រែជាគ្មានសុពលភាពដែរ។ ក្នុងករណីដែលពាក្យបណ្ដឹងជំទាស់ មិនមានសរសេរអំពីមូលហេតុនោះទេ ដើមបណ្ដឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់នោះទៅតុលាការនៃបណ្ដឹងជំទាស់ ក្នុងអំឡុងពេល ០២ សប្ដាហ៍ គិតពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ។ នៅពេលទទួលបានពាក្យបណ្ដឹងជំទាស់ តុលាការដើមត្រូវផ្ញើពាក្យបណ្ដឹងជំទាស់និងសំណុំរឿង ទៅតុលាការនៃបណ្ដឹងជំទាស់ ឱ្យបានឆាប់រហ័ស។ ពេលដែលបានទទួលនូវការផ្ញើពាក្យបណ្ដឹងជំទាស់ហើយ តុលាការនៃបណ្ដឹងជំទាស់ត្រូវពិនិត្យពាក្យបណ្ដឹងជំទាស់នោះហើយប្រសិនបើមានចំណុចណាដែលមិនស្របនឹងទម្រង់ នោះត្រូវបង្គាប់ឱ្យដើមបណ្ដឹងជំទាស់ធ្វើការកែតម្រូវ។ ប្រសិនបើភាគី នោះមិនធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេតុលាការត្រូវលើចោលពាក្យបណ្ដឹងជំទាស់នោះដោយដីការសម្រេច។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយនូវប្រធានបទខាងលើយ៉ាងលំអិតដែលបានបកស្រាយអំពី បណ្តឹងឧបាស្រ័យ រួចមកហើយ ឃើញថាការសិក្សាស្រាវជ្រាវនេះ គឺស្រាវជ្រាវផ្តោតទៅលើការប្តឹងទៅតុលាការជាន់ខ្ពស់។ ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មាន ៣ ប្រភេទ គឺ ការប្តឹងទៅសាលាឧទ្ធរណ៍ ការប្តឹងទៅតុលាការកំពូល និងការប្តឹងជំទាស់។ ភាគីអាចជ្រើសរើសចំណាត់ការណាមួយដើម្បីធ្វើបណ្តឹងទៅតាមប្រភេទបណ្តឹងរបស់ខ្លួន។ ការប្តឹងទៅ តុលាការឧទ្ធរណ៍ និងការប្តឹងទៅតុលាការកំពូល គឺប្តឹងប្រឆាំងចំពោះ សាលក្រម ឬសាលដីកា។ ចំពោះការប្តឹងជំទាស់វិញ គឺប្តឹងប្រឆាំងចំពោះ ដីកាសម្រេច។

ដោយផ្អែកលើការស្រាវជ្រាវ នៅក្នុងអំឡុងពេលមួយដ៏សមរម្យមួយស្តីអំពី បណ្តឹងឧបាស្រ័យនេះសំខាន់ណាស់ដើម្បីការពារផលប្រយោជន៍ ដល់បុគ្គលគ្រប់រូបដែលទទួលរងនូវភាពមិនអស់ចិត្តនឹង សេចក្តីសម្រេចចុងក្រោយរបស់តុលាការជាន់ទាប (ខេត្ត/ក្រុង) ឬសាលាឧទ្ធរណ៍ និងចំពោះដីកាសម្រេចរបស់តុលាការថ្នាក់ក្រោម (ខេត្ត/ក្រុង) ឬសាលាឧទ្ធរណ៍។ ចំពោះបណ្តឹងឧបាស្រ័យនេះ គឺទាក់ទងតែទៅលើរឿងក្តីរដ្ឋប្បវេណីតែប៉ុណ្ណោះ ដូច្នេះមិនទាក់ទងទៅនឹងតុលាការយោធានោះទេ (តុលាការជាន់ទាប) ពីព្រោះតុលាការយោធា ដែលមានយុត្តាធិការទៅលើតែបទល្មើសយោធាណាដែលជាហេតុនាំអោយ តុលាការនេះមិនទាក់ទងនិងបណ្តឹងឧបាស្រ័យឡើយ។

ម្យ៉ាងវិញទៀតបណ្តឹងឧបាស្រ័យគឺ មានបណ្តឹង៣ ដែលភាគីអាចដាក់ពាក្យបណ្តឹង ហើយភាគីត្រូវជ្រើសរើសបណ្តឹងអោយសមស្របទៅនឹងចំណាត់ការរបស់ តុលាការដូចជាបណ្តឹងឧទ្ធរណ៍ បណ្តឹងជំទាស់ និងបណ្តឹងសាទុក្ខ។ ក្នុងបណ្តឹងទាំងបីនេះពួកវាសុទ្ធសឹងតែជាបណ្តឹងទៅតុលាការជាន់ខ្ពស់ នេះមិនមែនមានន័យថា មានតែបណ្តឹង ៣ នេះទេ ដែលអាចប្តឹងទៅតុលាការជាន់ខ្ពស់បាននោះទេ គឺនៅមានបណ្តឹងទៅតុលាការ ជាន់ខ្ពស់ដទៃទៀត ដែលមិនចាត់ទុកថាជាបណ្តឹងឧបាស្រ័យដែលមានបញ្ញត្តិក្នុងគន្ថីទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ទេ បណ្តឹងទាមទារអោយជំនុំជម្រះសារជាថ្មី ឬបណ្តឹងតវ៉ាជាដើម។ ជាទូទៅ បណ្តឹងឧបាស្រ័យ (បណ្តឹងឧទ្ធរណ៍ បណ្តឹងទាស់ និងបណ្តឹងសាទុក្ខ) ដែលអាចធ្វើឡើងបានលុះត្រាតែសេចក្តីសម្រេចចុងក្រោយ ឬដីកាសម្រេចមិនទាន់ចូលជាស្ថាពរតែប៉ុណ្ណោះ តែបណ្តឹងទាមទារអោយជំនុំជម្រះសារជាថ្មី និងបណ្តឹងតវ៉ា គឺធ្វើឡើងនៅពេលដែលសេចក្តីសម្រេចចុងក្រោយបានចូលជាស្ថាពរទៅហើយ។

ជាទូទៅនៅពេលដែលភាគីបានដាក់ពាក្យបណ្តឹងជំទាស់ទៅកាន់តុលាការ ចំពោះសេចក្តីសម្រេច ដែលចេញជាប្រភេទដីការសម្រេច (សាលាដំបូង ឬ សាលាឧទ្ធរណ៍) ឬ ការដាក់ពាក្យបណ្តឹងសាទុក្ខនោះ អានុភាពនៃការដាក់ពាក្យបណ្តឹងឧបាស្រ័យបែបនេះគឺ ធ្វើឱ្យមាននូវកាបង្អាក់នូវការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ ដែលត្រូវរង់ចាំនីតិវិធីបន្ត នៃបណ្តឹងឧបាស្រ័យនោះចប់សិន។ ជាការកត់ចំណាំមួយ គឺថា ចំពោះសេចក្តីសម្រេច (ដោយចេញដីកាសម្រេច) លើពាក្យបណ្តឹងជំទាស់នោះហើយគឺ មិនអាចប្តឹងជំទាស់ថ្មីម្តងទៀតបានទេ ហើយជាពិសេសទៅទៀតនោះគឺរាល់ដីកាសម្រេចរបស់តុលាការកំពូលគឺមិនអាចប្តឹងជំទាស់បានទេ ពីព្រោះវាជាសេចក្តីសម្រេចរបស់តុលាការថ្នាក់ខ្ពស់ជាងគេ មិនមានយុត្តាធិការណាខ្ពស់ជាងតុលាការកំពូលទេ ដែលស្របទៅនឹងន័យថា បណ្តឹងឧបាស្រ័យជាប្តឹងមួយប្រភេទដែលប្តឹងទៅតុលាការជាន់ខ្ពស់មានន័យថាការប្តឹងទៅឧបាស្រ័យទៅតាមឋានានុក្រមពីតូចទៅធំដែលច្បាប់បានចែង (សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល)។ ប៉ុន្តែការធ្វើបែបនេះ គឺធ្វើអោយរយៈពេលនៃការបន្តនីតិវិធីទៅលើរឿងក្តីរដ្ឋប្បវេណីនីមួយៗមានរយៈពេលយូរ ឬអូសបន្លាយនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលជាហេតុនាំអោភាគីនៅក្នុងរឿងក្តីនោះខាតបង់លុយកាក់ជាច្រើន ហើយថែមទាំងខាតបង់ពេលវេលាជាច្រើន។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏បណ្តឹងឧបាស្រ័យនេះ ពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់បុគ្គលគ្រប់រូបដែលជាភាគីដែលទទួលរងនូវភាពយុត្តិធម៌ពីការ ចេញសេចក្តីសម្រេចរបស់តុលាការជាន់ទាបនោះដែលនេះជានីតិវិធីមួយដេលការពារនូវភាពលំអៀង ឬមានការភាន់ច្រឡំរបស់តុលាការនៅពេលដំណើរការរឿងក្តី។ ជាពិសេសជាងនេះទៅទៀតគឺ ការទប់ស្កាត់នូវការចេញសេចក្តីសម្រេចរបស់តុលាការដោយ ទំនើងចិត្តរបស់ចៅក្រមតុលាការជាន់ទាប ឬជួយឱ្យមានភាពល្អប្រសើរចំពោះ ការចេញសេចក្តីសម្រេច គ្រប់តុលាការជាន់ទាបទាំងអស់ត្រូវតែ គោរពតាមភាពយុត្តិធម៌ និងមានភាពត្រឹមត្រូវច្បាស់លាស់មិនលំអៀងជូនប្រជាពលរដ្ឋ។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវ នូវប្រធានបទខាងលើនេះរួចមកហើយ យល់ឃើញថាវាមានទាំងចំណុចវិជ្ជមាន និងមានទាំងចំណុចអវិជ្ជមានដោយសូមផ្តល់អនុសាសន៍ដូចខាងក្រោម។

ចំពោះបញ្ហាដែលទាក់ទងទៅនឹងការធ្វើបណ្តឹងឧបាស្រ័យ គឺភាគីដែលបានបាត់បង់ផលប្រយោជន៍ គឺមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែអ្វីដែលគួឱ្យចាប់អារម្មណ៍ត្រង់ថាតុលាការជាន់ខ្ពស់ គឺមានតែនៅរាជធានីភ្នំពេញ ដែលជាផលវិបាកសម្រាប់ប្រជាជនដែលនៅតាមខេត្ត ដែលចំណាយទាំងពេលវេលា លុយកាក់ច្រើន និងមធ្យោបាយធ្វើដំណើរ។ ដើម្បីសម្រួលដល់ប្រជាជន និងសម្រួលដល់ការងាររបស់តុលាការកុំឱ្យមានភាពរាំងស្ទះក្នុងដំណើរការនៃនីតិវិធីមានការយឺតយ៉ាវ និងដើម្បីចេញសេចក្តីសម្រេចឱ្យបានឆាប់រហ័សជូនប្រជាជន។ ក្នុងករណីដែលប្រជាជនដែលមានបំណងចង់ធ្វើបណ្តឹងឧបាស្រ័យ គឺពួកគាត់មានផលវិបាកខ្លាំងណាស់ដែលពួកគាត់រងចាំនូវសេចក្តីសម្រេចដោយរឿងក្តីជាច្រើនដែលប្រមូលផ្តុំនៅតុលាការជាន់ខ្ពស់ រដ្ឋហាក់បីដូចជាមើលរំលងនូវចំណុចនេះ ហើយគ្មានវិធានការសោះដើម្បីបង្កើតតុលាការជាន់ខ្ពស់នៅតាមខេត្ត។

ហេតុដូច្នេះ ទាក់ទងនឹងការធ្វើបណ្តឹងឧបាស្រ័យរបស់ប្រជាជនគួតែមានតុលាការជាន់ខ្ពស់នៅតាមខេត្ត ដើម្បីឱមានភាពងាយស្រួលដល់ប្រជាជន និងសម្រួលដល់ការងារតុលការឱ្យបានឆាប់រហ័សក្នុងការចេញសេចក្តីសម្រេចជូនប្រជាជន។

ចំពោះបញ្ហាមួយចំនួនទៀតដែលពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ គឺថាតុលាការគួតែជាតុលាការឯករាជ្យ ពីព្រោះដោយសារតែមានភាពមិនទុកចិត្តរបស់ប្រជាជន ដែលថាតុលាការជាស្ថាប័នមួយដែលដែលស្ថិតនៅក្រោមស្ថាប័នផ្សេង ហេតុនេះហើយប្រសិនបើមិនមានការរៀបចំលើប្រព័ន្ធតុលាការឱ្យមានភាពត្រូវនោះទេ វានឹងធ្វើឱ្យមានការបាត់បង់ទំនុកចិត្តរបស់ប្រជាជនដែលជាបញ្ហារបស់សង្គមទាំងមូល។

# ឯកសារយោង


- JUN UCHIYAMA. ២០១៨. បណ្ដឹងសាទុកក្នុងបណ្ដឹងរដ្ឋប្បវេណី។
- កេត សុជាតិ. ២០១៥. *នីតិវិធីរដ្ឋប្បវេណី*។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ២០០៨. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃ ក្រមនីតិវិធីរដ្ឋប្បវេណី៖ នីតិវិធីបណ្ដឹង និងការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ.* ភ្នំពេញ៖ ការិយាល័យកម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និងតុលាការនៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. ២០០៨. *សេចក្ដីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណី៖ នីតិវិធីបណ្ដឹង និងការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ.* ភ្នំពេញ៖ ការិយាល័យកម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និងតុលាការនៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រមក/០៧១០/០១៣, ០៩ មិថុនា ឆ្នាំ២០១០។
- ជួន ណាត. ១៩៦៧. *វចនានុក្រមខ្មែរ.* ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត។
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- សារណាបញ្ចប់ការសិក្សាឆ្នាំ២០១១ (បណ្ដឹងឧបាស្រ័យ)
- សេង វុធ្ធី.២០០៩. លំហូរនីតិវិធីរឿងក្ដីរដ្ឋប្បវេណីក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១។
- អ៊ីវ ប៉ូលី. ២០១១. *នីតិវិធីរដ្ឋប្បវេណី*។
- អ៊ីវ ប៉ូលី. ២០១៨. បណ្ដឹងឧទ្ធរណ៍។

# ឧបសម្ព័ន្ធ